BMI0199

# សម្ភាសន៍ជាមួយឈ្មោះ យិន វ៉ុន ភេទស្រី អាយុ៤៧ឆ្នាំ

មុខងារសម័យខ្មែរក្រហមៈ កាត់ដេរ

ស្រុកកំណើតនៅភូមិស្រែចែង ឃុំស្រែក្នុង ស្រុកជុំគីរី ខេត្តកំពត

និង សម្ភាសន៍ជាមួយឈ្មោះ សាន ទូច ភេទប្រុស អាយុ៥៣ឆ្នាំ

ត្រូវជាប្ដីរបស់ឈ្មោះ យិន វុន

សព្វថ្ងៃរស់នៅភូមិត្រសេកជ្រុំ ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១០

សម្ភាសន៍ដោយៈ ឆាយ ឈុនលី

០១:០៣:០៤

៣៨ទំព័រ

ឈុនលី ៖ សុំសួរឈ្មោះមីងៗឈ្មោះអីដែរ?

វ៉ុន ៖ វុនៗ

ឈុនលី ៖ ត្រកូលនោះ?

វ៉ុន ៖ យិន វុនៗ

ឈុនលី ៖ វុន ហើយវ៉ន់?

វ៉ុន ៖ វុនៗ

ឈុនលី ៖ អាយុប៉ុន្មាន?

វ៉ុន ៖ អាយុ៤៧ៗ

ឈុនលី ៖ នៅនេះគេហៅភូមិ?

វ៉ុន ៖ ត្រសេកជ្រុំៗ

ឈុនលី ៖ ឃុំម៉ាឡៃៗ ខ្ញុំចង់ដឹងរឿងរ៉ាវរបស់មីង ដូចថាតាំងពីតូច រឿងរ៉ាវតាំងពីក្មេងមករហូតដល់ធំឆ្លងកាត់សម័យសង្គ្រាមច្រើនគន់ ហើយបានឆ្លងដល់សម័យ៣ឆ្នាំ៨ខែទៀតៗ ហើយពិសេសទៀត ខ្ញុំចង់ដឹងបន្ទាប់ពី៧៩មកដល់ឥឡូវហ្នឹង ចង់ដឹងការរស់នៅម៉េចៗអីចឹង?

វ៉ុន ៖ ពីមុន៧៩?

ឈុនលី ៖ ចា៎! មីងកើតហ្នឹងនៅខេត្តកំពតទេ?

វ៉ុន ៖ ខ្ញុំនៅកំពតនោះៗ

ឈុនលី ៖ ស្រុកកំណើតនៅភូមិអីគេ?

រ៉ុន ៖ នៅភូមិស្រែចែង ស្រុកស្រែក្នុង ។

ឈុនលី ៖ ស្រុកស្រែក្នុង អាហ្នឹងឃុំ ឬក៏ស្រុក?

រ៉ុន ៖ ឃុំ ស្រុកស្រែចែង ឃុំស្រែក្នុង ។

ឈុនលី ៖ ស្រុក?

រ៉ុន ៖ អឺ!

ឈុនលី ៖ ស្រែក្នុង?

រ៉ុន ៖ ចាំ! ស្រុកស្រែចែង ឃុំស្រែក្នុង ។

ឈុនលី ៖ ភូមិអីគេទៅ?

រ៉ុន ៖ ភូមិអីគេ ហ៎!ភូមិស្រែចែងហ្នឹង ។

ឈុនលី ៖ ស្រែចែងខ្ញុំអត់ដែលឮនៅកំពត?

រ៉ុន ៖ ជំនាន់នឹងគេហៅ ប៉ុនឥឡូវបែបអត់ ជំនាន់ហ្នឹងគេឥឡូវគេដូរស់ឈ្មោះអស់ហើយ ឥឡូវអត់ដឹងគេហៅឈ្មោះអីៗ ។

ឈុនលី ៖ ចាំ! ដូចអត់ដែលឮមែន ។

រ៉ុន ៖ ឥឡូវគេដាក់ឈ្មោះថ្មីទាំងអស់ ដឹងឈ្មោះអីៗ ខ្ញុំបានទៅតាំងពីជំនាន់ខ្ញុំនៅកុមារនៅគេយកខ្ញុំទៅនៅភ្នំពេញតាំងពី៧៨មក ។

ឈុនលី ៖ អ្នកណាគេយកទៅ?

រ៉ុន ៖ ជំនាន់ហ្នឹងដែរគេ មើល៧៧ខ្ញុំទៅនៅតាកែវនៅកាត់ដេរហ្នឹងឯង ។

ឈុនលី ៖ ចុះ៧៥នោះ?

រ៉ុន ៖ ៧៥នៅកំពតហ្នឹងឯង នៅកុមារកាត់ដេរនៅកំពតហ្នឹងឯង ។

ឈុនលី ៖ នៅកងកុមារ កាលហ្នឹងអាយុប៉ុន្មាន?

រ៉ុន ៖ នៅមន្ទីរ១កន្លែងកាត់ដេរហ្នឹងឯង ។

ឈុនលី ៖ កាលហ្នឹងអាយុប៉ុន្មាន ៧៥?

រ៉ុន ៖ កាលហ្នឹងអាយុ៧៥ ខ្ញុំអាយុ១០ឆ្នាំ ហ៎!៧៤ ១០ ១១ហើយ៧៥ ៧៤ អាយុ១០ឆ្នាំ ។

ឈុនលី ៖ នៅក្នុងមន្ទីរកុមារ?

រ៉ុន ៖ មន្ទីរកុមារ នៅកន្លែងកាត់ដេរហ្នឹង ។

ឈុនលី ៖ ធ្វើអីខ្លះទៅ?

រ៉ុន ៖ ដាក់ខ្សែរអាវ គេឲ្យនៅដាក់ខ្សែរអាវ ហើយ៧៨គេឲ្យដេរ ទៅនៅតាកែវ ៧៨គេឲ្យទៅយកទៅនៅតាកែវ ។

ឈុនលី ៖ ចុះ៧៦?

រ៉ុន ៖ ៧៦នៅកំពតហ្នឹងឯង នៅហ្នឹងផ្សារហ្នឹងម៉ង នៅកាត់ដេរក្នុងផ្សារហ្នឹង ។

ឈុនលី ៖ ហា៎!នៅផ្សារ ក្នុងពេលហ្នឹងសម័យប៉ុលពតហើយ មែនអត់?

រ៉ុន ៖ ហ្នឹងហើយ តែដល់ពេល៧៨គេយកខ្ញុំទៅនៅតាកែវ គេឲ្យខ្ញុំដេរហើយខ្ញុំធំហើយនោះឲ្យខ្ញុំដេរ ។ នៅបានប៉ុន្មានខែទេ ក៏គេយកមកនៅភ្នំពេញហ្នឹង៧៨ហ្នឹងដែរ ។

ឈុនលី ៖ ៧៦នៅតាកែវ?

រ៉ុន ៖ ៧៦នៅកំពត ។

ឈុនលី ៖ នៅកំពត?

រ៉ុន ៖ ចា៎! ៧៨យកទៅតាកែវ តែពាក់កណ្ដាល៧៨ហ្នឹងយកមកភ្នំពេញដែរ នៅបានប៉ុន្មានខែយកទៅកាត់ដេរហ្នឹង នៅបាន ។

ឈុនលី ៖ នៅតាកែវ៧៨ហ្នឹង កាត់ដេរដែរ?

រ៉ុន ៖ ចា៎! គេយកទៅកាត់ដេរៗបានប៉ុន្មាន ។

ឈុនលី ៖ កាត់ដេររបៀបរោងចក្រ?

រ៉ុន ៖ អត់រោងចក្រទេមន្ទីរ គេហៅមន្ទីរគេម៉ង គេធ្វើ ។

ឈុនលី ៖ ចា៎! កាត់ដេរខោអាវពណ៌ខ្មៅហ្នឹង?

រ៉ុន ៖ ចា៎! ដេរខោអាវពណ៌ខ្មៅៗហ្នឹង ដេរសារុង ដេរសំពត់ខ្មៅ ដេរអាវខ្មៅយើងជំនាន់នេះហ្នឹង ដេរខោចែវដេរខោអីហ្នឹង ។ ក៏ពាក់កណ្ដាលឆ្នាំគេយកខ្ញុំទៅនៅភ្នំពេញទៀត ។

ឈុនលី ៖ ហើយទៅនៅភ្នំពេញ អន្លាល់ហ្នឹងមីងមានបងប្អូនប៉ុន្មាននាក់?

រ៉ុន ៖ បងប្អូន២នាក់ បងប្អូនទៅនៅហ្នឹងគេយកទៅទាំង២ ។

ឈុនលី ៖ ស្រីៗ២នាក់?

រ៉ុន ៖ ស្រីទាំង២ហ្នឹង ។

ឈុនលី ៖ ចុះឪពុកម្ដាយ?

រ៉ុន ៖ ឪពុកម្ដាយខ្ញុំនៅកំពតហ្នឹង នៅស្រុកហ្នឹង ។

ឈុនលី ៖ ហើយចុះដល់ពេលមីងមកនៅភ្នំពេញអីចឹង?

រ៉ុន ៖ នៅភ្នំពេញ គេយក ។

ឈុនលី ៖ ពួកគាត់អត់មក?

រ៉ុន ៖ អត់ ម៉ែខ្ញុំនៅស្រុកនោះឯង ខ្ញុំមកនៅភ្នំពេញហើយក៏ ។

ឈុនលី ៖ ចុះបងរបស់មីង?

រ៉ុន ៖ បងខ្ញុំនៅបាត់ដំបង ប៉ុនបាត់ឈ្មោះតាំងអង្គាល់៧៩បាត់មិនដឹងទៅណា រកអត់ឃើញស្លាប់ហើយ ។

ឈុនលី ៖ ចុះមីងដែរសួរសុខទុក្ខឪពុកម្ដាយ?

រ៉ុន ៖ ទៅ ម៉ែឪខ្ញុំមកហ្នឹងដែរហ្នឹង គាត់ស្លាប់អស់ហើយ ជំនាន់នេះស្លាប់អស់ហើយ ។

ឈុនលី ៖ មកនៅភ្នំពេញធ្វើអីទៀត?

រ៉ុន ៖ មកទៅនៅភ្នំពេញគេយកទៅនៅបម្រើភ្ញៀវ បម្រើអីហ្នឹង ។

ឈុនលី ៖ ម៉េចទៅ?

រ៉ុន ៖ ទៅនៅកន្លែងមន្ទីរមានភ្ញៀវមានអីមកណា៎ ពួកបរទេសគេមក គេឲ្យទៅបម្រើ ។

ឈុនលី ៖ ដូចគណៈប្រតិភូគេមក?

រ៉ុន ៖ ចា៎! ហ្នឹងហើយ ពួកកូរ៉េ ពួកចិន ពួកអីគេមកនៅខ្មែរយើងហ្នឹង គេឲ្យទៅ ។

ឈុនលី ៖ បម្រើម៉េចទៅ?

រ៉ុន ៖ យើងរៀបតាមបន្ទប់ តាមអីកន្លែងគេដេកណា៎ ។ ហើយដល់ដូចគេជប់លៀងគេហូបបាយហូបទឹកអីចឹង យើងលាងចានលាងអីទៅ ពេលគេហូបបាយហើយ យើងលើកចានលើកអីមកលាងមក ហ្នឹងនៅកន្លែងបម្រើភ្ញៀវ ។

ឈុនលី ៖ ចុះដល់ពេល៧៩?

រ៉ុន ៖ ៧៩ យើងយួនចូលរត់មកនៅតាមព្រំដែននេះ ។

ឈុនលី ៖ ម៉េចបានមកខាងហ្នឹងវិញ?

រ៉ុន ៖ ដឹង ពួកមន្ទីរហ្នឹងគេឲ្យយើងរត់មកៗបេះរត់ចូលព្រៃចូលអីដាច់បាយ ដាច់ទឹករាប់ឆ្នាំរាប់ខែហ្នឹងមក ឡើងឈឺចង់ងាប់ ខ្ញុំគ្មានថារស់ផង ជ្រុះសក់ ។

ឈុនលី ៖ រត់មកនៅជាមួយខ្មែរក្រហមហ្នឹង?

រ៉ុន ៖ រត់ចា៎! បេះរត់មកនៅខាងប៉ៃលិននោះ គេឲ្យនៅហ្នឹងនៅដឹកជញ្ជូន គេឲ្យជញ្ជូនគ្រាប់ជញ្ជូនអីហ្នឹង ជញ្ជូនគ្រាប់ឲ្យពួកទ័ពគេវ៉ៃគ្នាហ្នឹងណា ។ ជញ្ជូនចឹងទៅដល់ ។

ឈុនលី ៖ ជម្លៀសម៉ាមន្ទីរម៉ង់មីង ហើយក៏ម៉េច?

រ៉ុន ៖ អត់ទេ រត់មកបែកគ្នានៅម្នាក់ ២នាក់ចេះរត់ទៅ ។

ឈុនលី ៖ ហេតុអីបានមីងមកខាងនេះវិញអីចឹង គេនៅផ្សេង?

រ៉ុន ៖ ខ្ញុំរត់មកតាមប៉ៃលិនហ្នឹងមក ដល់ហើយខ្ញុំនៅរត់មកហ្នឹងគេឲ្យនៅខាងដឹកជញ្ជូនហ្នឹង ដល់ពេលមានប្ដីទៅ អឺ!ពេលនេះប្ដីខ្ញុំគាត់ទៅដណ្ដឹងខ្ញុំ ការនៅហ្នឹង ។

ឈុនលី ៖ ឆ្នាំណា?

រ៉ុន ៖ ៧៩ ខែ អឺ!៨០ ។

ឈុនលី ៖ ចឹងពេលចេញពីភ្នំពេញមក មកជុំគ្នា?

រ៉ុន ៖ ចេញពីភ្នំពេញមកៗនៅប៉ៃលិនហ្នឹង ហើយខ្ញុំនៅដឹកជញ្ជូនគាត់នៅទ័ពស្គាល់គ្នាគាត់ដណ្ដឹង ។

ឈុនលី ៖ ដឹកជញ្ជូនអីគេ?

រ៉ុន ៖ ជញ្ជូនគ្រាប់ ។

ឈុនលី ៖ ពេលច្បាំងជាមួយពួករដ្ឋបាលហ្នឹង?

រ៉ុន ៖ ចា៎! ទួលអង្ករ ទួលអី ឲ្យទ័ពទៅណា ។

ឈុនលី ៖ អីទៀតទៅមីង?

រ៉ុន ៖ ដល់ពេល គាត់ដណ្ដឹងបានហើយ បានគ្នាការហើយ ខ្ញុំការឯប្រាំង ។

ឈុនលី ៖ ប្ដីឈ្មោះអីគេមីង?

រ៉ុន ៖ ឈ្មោះតូច សាន់ តូច ។

ឈុនលី ៖ ឥឡូវហ្នឹងនៅរហូតមកដល់ឥឡូវ?

រ៉ុន ៖ ចា៎! នៅមិញប្ដីរបស់ខ្ញុំឈរ ។

ឈុនលី ៖ អូ! គាត់ធ្វើទ័ព?

រ៉ុន ៖ ការហើយមកនៅហ្នឹង ការហើយមកនៅភូមិដូងហ្នឹង តាយ៉ានគាត់យកមកនៅហ្នឹងម៉ង ។

ឈុនលី ៖ ចុះដល់ពេលនៅប៉ៃលិនយូរទេ?

រ៉ុន ៖ នៅប៉ៃលិន នៅតិចខែដែរហ្នឹង អត់បានគិតផង ដឹងប៉ុន្មានខែ នៅប៉ៃលិនហ្នឹង នៅដាំបាយឲ្យអ៊ំអៀង សារីហ្នឹង ជំនាន់ហ្នឹង ។

ឈុនលី ៖ កាលហ្នឹងក្រោមការគ្រប់គ្រង?

រ៉ុន ៖ ចា៎! ជំនាន់ហ្នឹងនោះ នៅដាំបាយដាំអី ។

ឈុនលី ៖ នៅច្រើនខែ?

វ៉ុន ៖ ចាំ! នៅប៉ុន្មានខែ៣-៤ខែហ្នឹងឯង ក៏ខ្ញុំមកនៅតាមកងមក ក៏បានគ្រួសារទៅ ខ្ញុំគេយកមកនៅហ្នឹង អ្នកនៅភូមិដូងហ្នឹង។ កាលហ្នឹងគេហៅភូមិដូង យើងត្រង់ហ្នឹង។

ឈុនលី ៖ ភូមិដូងទេ អានេះ?

វ៉ុន ៖ ចាំ! ត្រង់ហ្នឹងគេហៅភូមិដូង យើងត្រង់ហ្នឹង។

ឈុនលី ៖ ភូមិដូងនេះ?

វ៉ុន ៖ ចាំ! ត្រង់ហ្នឹងគេហៅភូមិដូង នោះអាត្រង់ខាងក្រោយវត្តធំមូលចេះ។

ឈុនលី ៖ ត្រសេកជ្រុំ?

វ៉ុន ៖ ចាំ! កាលហ្នឹងខ្ញុំនៅ។

ឈុនលី ៖ ចឹងអានេះភូមិដូងវិញ?

វ៉ុន ៖ អត់ទេ កាលអីនៅខាងនោះ ដល់ពេលឥឡូវនេះ គេដាក់ភូមិនៅតាមពីមុនមិនទាន់រៀបភូមិរៀបអីចឹងទេ ឥឡូវនេះៗភូមិមកនេះត្រសេកជ្រុំ។ កាលមុននៅនោះ កន្លែងធ្វើកង់នោះដីក្រោយ ជិតផ្សារ។

ឈុនលី ៖ ចឹងពេលមឹងការអីហើយ ចឹងពេលនៅប៉ែលិនហ្នឹង ក្រោមការគ្រប់គ្រងរបស់អៀងសារី?

វ៉ុន ៖ ចាំ! នៅ។

ឈុនលី ៖ ហើយអ្នកណាទៀតទៅ?

វ៉ុន ៖ ខ្ញុំនៅជាមួយគេ ដឹងមួយណែខ្លះទេ គេមេៗ អត់សូវស្គាល់គេផង គ្រាន់គេឲ្យនៅធ្វើបាយធ្វើទឹកចេះនៅធ្វើហ្នឹងគេ។ ដល់ពេលបានប្ដីមក ក៏ខ្ញុំមកនៅតាមប្ដីខ្ញុំមក ចេះនៅនេះចឹងទៅ។

ឈុនលី ៖ ចុះមឹងមានដឹងអ្នកណាគេដែលថ្នាក់ក្រោមគាត់ទៀតអីអត់?

វ៉ុន ៖ អត់ដឹងផង អត់ស្គាល់ច្រើនគ្នា មិនដឹងណាណែខ្លះផង។ ពេលអ៊ុកឡុងឆោឡោចចឹងទៅឃើញតែគេមេៗ ដល់ពេលអាយើងនេះខ្លាច គេជម្លៀសទៅស្រុកថៃអស់។ ខ្ញុំក៏នៅដឹកជញ្ជូនទៅណា ហើយគេទៅអស់ មេទៅអស់ខ្ញុំនៅដឹកជញ្ជូន។

ឈុនលី ៖ មឹងដល់ពេលមកនៅម៉ាឡៃនេះ មកជាមួយអ្នកណាគេខ្លះ?

វ៉ុន ៖ មកជាមួយប្ដីខ្ញុំហ្នឹង គាត់មកយកមកនៅហ្នឹងរហូតនៅតាមគាត់។

ឈុនលី ៖ ហើយជាមួយអ្នកណាទៀត អ្នកស្រុកផ្សេងទៀត?

វ៉ុន ៖ នៅចេះនៅច្របូកច្របល់ពេញហ្នឹង ដឹងអ្នកនៅខាងណាខាងណែអីចេះមកជុំគ្នាចឹងទៅ។

ឈុនលី ៖ ច្រើនគ្រួសារ?

វ៉ុន ៖ ចា៎! នៅច្រើន នៅពេញហ្នឹងទៅ។

ឈុនលី ៖ ចុះស្ថានភាពពេលហ្នឹងម៉េចដែរ នៅស្រុកម៉ាឡៃ?

វ៉ុន ៖ អត់អីផង តាំងពីមកនៅហ្នឹងអត់អី សប្បាយ។

ឈុនលី ៖ អត់ទេនិយាយថាឆ្នាំ៧៩ពេលមកហ្នឹង នៅស្រុកម៉ាឡៃហ្នឹងម៉េចទៅ សុទ្ធតែព្រៃ សុទ្ធតែអីចឹង?

វ៉ុន ៖ អូ! សុទ្ធតែព្រៃមីន មកដំបូងសុទ្ធតែមីន។

ឈុនលី ៖ ហើយចឹងខ្លាចទេ?

វ៉ុន ៖ ខ្លាច មិនហ៊ានដែលមើលគេជិនាន់ដែលយួនវ៉ៃហ្នឹងមិនរត់នៅ៨៥នោះ។

ឈុនលី ៖ អូ!

វ៉ុន ៖ ទៅនៅស្រុកថៃ។

ឈុនលី ៖ ជំរំស្រុកថៃ?

វ៉ុន ៖ ចា៎! ទៅនៅហ្នឹង ពេលគេដឹកមកវិញ គេឈូសឲ្យយើងនៅដាក់ប្រជាជន ឈូសគេរាវមីនឲ្យស្អាតទៅ។

ឈុនលី ៖ អ្នកណាអ្នករាវ?

វ៉ុន ៖ ពួកអ្នកប្រធានៗមេទ័ពគេហ្នឹងយើង ពេលគេដាក់ម្តុំ ដល់ហើយអ្នកម្ចាស់ខ្លួនគេរាវខ្លួនឯងខ្លះ រាវខ្លះគ្នាផ្ទុះមីនត្រូវដាច់ជើងដាច់ដៃទៅ ហើយខ្លះខ្វាក់ភ្នែក។ ហើយខ្ញុំអត់ហ៊ានរាវបាន អ្នកគេហ៊ានបានដីធំទៅ គេទៅរាវទៅ គេយកដីធ្វើផ្ទះធ្វើអីទៀតទៅ បានដីធំ។

ឈុនលី ៖ ធ្វើម៉េចរាវដឹងមីន?

វ៉ុន ៖ ដឹងគេធ្វើម៉េច ខ្ញុំអត់ដឹងដែរ។

ឈុនលី ៖ ចុះដីមីន កាលមកនៅដំបូងនៅនេះ?

វ៉ុន ៖ ខ្ញុំមានត្រឹមនេះ កូនខ្ញុំទិញគេ នេះផ្ទះកូន ផ្ទះខ្ញុំនៅត្រង់នោះ ហើយខ្ញុំលក់ដីកន្លែងគេឲ្យ។

ឈុនលី ៖ ហើយមានមីនទេ អាដីហ្នឹង?

វ៉ុន ៖ មាន ពេលដល់ហើយគេឲ្យសាម៉ីម៉ៃម៉ែខំម៉ៃម៉ែអីគេដើររកិនដើរអីទៀតទៅ ដល់ហើយមានគ្រាន់យើងមានអាសាម៉ីគេរុញ គេកិនចឹងទៅ វាអត់នេះទេ មនុស្ស។

ឈុនលី ៖ ចឹងពេលកិនទៅមិនផ្ទុះ?

រ៉ុន ៖ ផ្ទះ ប៉ុនវាអត់អី កិនទៅផ្ទះផុចៗចឹងទៅអាសាមុីហ្នឹងគេនៅក្នុងកញ្ចក់ចឹងអត់អី មិនណាស់តាមនេះមិនច្រើនមែនទែន ។

ឈុនលី ៖ ហើយដល់ពេលមកនៅចឹងសុទ្ធព្រៃអីចឹង ហើយបានអីហូបចុកទៅ?

រ៉ុន ៖ ជំនាន់ហ្នឹងគេបើក ជំនាន់មកនៅមុនដំបូងបើកអង្ករ ។

ឈុនលី ៖ បើកពីណាមកវិញ?

រ៉ុន ៖ បើកនៅកន្លែងមន្ទីរនៅខាងនេះផ្សារហ្នឹង កន្លែងជិតផ្សារ កាលនឹងដឹងគេដឹកពីណាមកទេ មិនសូវដឹងដែរ ដឹកមកឃើញពេលនេះម៉ាខែគេបើកឲ្យម្ដង ។

ឈុនលី ៖ ចុះអ្នកណាមេដឹកនាំឲ្យមកនៅហ្នឹងម៉ង?

រ៉ុន ៖ ដឹងមេណាទេ ខ្ញុំមិនសូវស្គាល់ទេ ។

ឈុនលី ៖ គាត់អ្នកនាំថាឥឡូវឲ្យមកនៅស្រុកម៉ាឡៃ អីចឹងបានយើងហ៊ានមក ទាល់តែគាត់ឲ្យមក?

រ៉ុន ៖ ចា៎! កាលហ្នឹងគេដឹកមក កាលហ្នឹងមានឈ្មោះពូនីៗគាត់ ដែលគណៈស្រុកនេះឥឡូវគាត់អន្តត់ជើង គាត់ឈប់នៅនេះ ដឹងទៅនៅណាបាត់ហើយពូនីហ្នឹង ។

ឈុនលី ៖ នីត្រកូលអីគេ?

រ៉ុន ៖ ពូនីមេទ័ព ដឹងឈ្មោះអី អត់ដែលស្គាល់ដែរហ្នឹង តែឥឡូវគាត់ឈប់ គេអត់ឲ្យទៅស្រុកនេះ ទៅនៅស្រុកណាបាត់ហើយ ។

ឈុនលី ៖ ចឹងគាត់មេទ័ព គាត់ដឹកនាំឲ្យមក?

រ៉ុន ៖ ចា៎! ហ្នឹងហើយកាលហ្នឹងគាត់ដឹកទ័ពមកនៅហ្នឹង តានីហ្នឹងគាត់អន្តត់ជើង កាលមុនគាត់មេទ័ព មេធំជាងគេ ដល់គាត់ផ្ទុះមីនដាច់ជើង ។

ឈុនលី ៖ ឥឡូវហ្នឹងផ្ទុះមីនដាច់ជើង?

រ៉ុន ៖ ផ្ទុះដាច់យូរណាស់ហើយ តាំងពីយើងមកតាមព្រំដែនហ្នឹង ។

ឈុនលី ៖ តែឥឡូវនៅណា?

រ៉ុន ៖ ដឹងនៅណា គេដកចេញ ពីមុនគាត់ធ្វើប្រធានស្រុកហ្នឹង ឥឡូវដាក់ឲ្យតាណាលធ្វើ ។

ឈុនលី ៖ ប្រធានស្រុក អឺ!ចៅហ្វាយស្រុក?

រ៉ុន ៖ ចា៎!គាត់ពីមុនគាត់កាន់ទ័ព ដល់ពេលគេឲ្យគាត់ធ្វើចៅហ្វាយស្រុក ដល់ក្រោយមកគាត់ឲ្យ ។

ឈុនលី ៖ ធ្វើចៅហ្វាយស្រុកពេលណា?

រ៉ុន ៖ ធ្វើកាលឆ្នាំ៩០ប៉ុន្មានទេ ខ្ញុំភ្លេចអស់ហើយ អត់សូវចាំបានយូរ គេដកគាត់ឲ្យទៅនៅកន្លែងផ្សេង គេឲ្យតាណាលហ្នឹងគាត់ធ្វើម្ដង ។

ឈុនលី ៖ តាណាល់ហ្នឹងគាត់ឡើងតាំងពីឆ្នាំណា?

រ៉ុន ៖ ដឹងឆ្នាំទីប៉ុន្មាន ខ្ញុំអត់ចាំ ខ្ញុំមិនបានគិត ដកតានីហ្នឹងចេញដាក់តាណាល់ហ្នឹង អត់ចាំទេ ដល់សួរមេប្រធានភូមិបានគាត់ដឹង ខ្ញុំអត់ចាំទេ ។

ឈុនលី ៖ ចុះមានអ្នកណាទៀត ក្រៅពីតានីហ្នឹង?

រ៉ុន ៖ អត់ កាលហ្នឹងមានតានីហ្នឹងហើយ ឃើញដកគាត់ចេញទៅនៅពីកន្លែងផ្សេងឲ្យតាណាល់ហ្នឹងឡើងនេះហ្នឹង ។

ឈុនលី ៖ ចឹងតាណាល់ហ្នឹងឡើងយូរហើយ?

រ៉ុន ៖ ឡើងយូរដែរហើយ ។

ឈុនលី ៖ ថាខ្ទង់៨០ទេ ឆ្នាំ៨០ហើយ៩០?

រ៉ុន ៖ ហ៎! កាលឆ្នាំ៨០តានីនៅ ។

ឈុនលី ៖ មក៩០ជាង?

រ៉ុន ៖ ៥-៦ឆ្នាំហើយ ។

ឈុនលី ៖ ចុះអាពេលមីងមកពីជំរំវិញ គាត់នៅហ្នឹងទេ តានី?

រ៉ុន ៖ តានីហ្នឹងនៅហ្នឹងទើបដកចេញ គេយកទៅនៅ ។

ឈុនលី ៖ ក្រោយសមាហរណកម្មទេ?

រ៉ុន ៖ បោះឆ្នោត គេបោះឆ្នោតអត់ជាប់ ដឹងគាត់ទៅនៅណាទេ គេដកគាត់ទៅនៅកន្លែងផ្សេង កាលហ្នឹងបានបោះឆ្នោតឲ្យអត់ជាប់គាត់ ។

ឈុនលី ៖ ចឹងពេលគាត់ធ្វើសមាហរណកម្ម?

រ៉ុន ៖ ធ្វើអីវិញ?

ឈុនលី ៖ អាពេលគេធ្វើសមាហរណកម្មម៉ង អាពេលគេចូល ពេលខ្មែរក្រហមផ្ដាច់ខ្លួន?

រ៉ុន ៖ អូ! អាពេលផ្ដាច់ខ្លួន ចា៎! ហ្នឹងហើយគេដកជំនាន់ផ្ដាច់ខ្លួនហ្នឹងហើយ តាណាល់ហ្នឹងកាន់កាប់ធ្វើចៅហ្វាយស្រុក គណៈស្រុកហ្នឹង ។

ឈុនលី ៖ ចឹងពេលហ្នឹងសម្ដេចមកអីចឹង?

រ៉ុន ៖ ចា៎! ហ្នឹងហើយកាលហ្នឹងសម្ដេចហ៊ុនសែន មកៗយើងហ្នឹង តាណាល់ធ្វើចៅហ្វាយស្រុក ។

ឈុនលី ៖ មីងៗអាចរៀបរាប់បានទេ ពេលមកនៅចឹង បើកអង្ករបើកអីបើកពីណាវិញដំបូង?

រ៉ុន ៖ ជំនាន់ហ្នឹងមិនដឹងពីណាមកវិញ មិនសូវដឹងនឹងគេដងខ្ញុំ ។

ឈុនលី ៖ បានអីគេខ្លះ កាលហ្នឹងៗគេឲ្យ?

រ៉ុន ៖ ជំនាន់ហ្នឹងបើកតែអង្ករហូប គ្មានបើកអីផងៗ

ឈុនលី ៖ ម្ហូប?

រ៉ុន ៖ កាលពេលជំនាន់នៅវ៉ែក្មា បើកត្រីខ បើកអី ប៉ុន្មានត្រីខ២-៣ថ្ងៃ អឺ!ម៉ាខែចឹងបាន២-៣កំប៉ុង ណាបើកមីបើកអីហ្នឹងៗ

ឈុនលី ៖ អានៅវ៉ែក្មាហ្នឹងឆ្នាំណា មីងថា?

រ៉ុន ៖ ៧៩ អឺ!ជំនាន់នៅដីថៃនៅជំរំ បើនៅនេះអត់មានបើកអីទេ បើកតែអង្ករ ដល់យើងផ្តាច់ខ្លួនទៅ លែងមាន យើងទិញហូបខ្លួនឯងៗ ផ្តាច់ខ្លួនហ្នឹងយើងហូបក្រោយ ទិញអីៗហូបខ្លួនឯងៗ

ឈុនលី ៖ ចុះមីងទៅថៃហ្នឹងឆ្នាំណា?

រ៉ុន ៖ ៨០ អឺ!៨៥ គេយកទៅដាក់ជំរំឆ្នាំ៨៥ៗ

ឈុនលី ៖ អាហ្នឹងមកវិញ ឬក៏ទៅ?

រ៉ុន ៖ ពេលទៅនៅហ្នឹងឯង ទៅនៅហ្នឹងឆ្នាំហ្នឹងឯងៗ

ឈុនលី ៖ ចុះមកវិញពេលណា?

រ៉ុន ៖ ទៅនៅហ្នឹងម៉ាឆ្នាំៗ

ឈុនលី ៖ ៨៦មកវិញ?

រ៉ុន ៖ ចា៎! ៨៦ ៨៧ ២ឆ្នាំ ៨៧បានមកនៅនេះវិញៗ

ឈុនលី ៖ ចុះមីងដឹងរឿងគេដាក់មីនដាក់អីហ្នឹង អ្នកណាគេអ្នកដាក់?

រ៉ុន ៖ មីនហ្នឹងមិនដឹងខាងទ័ពយួនដាក់ ឬក៏ទ័ពយួនដាក់ទេ ដាក់ការពារ ដាក់ទាំងអស់គ្នា ដាក់ការពារដូចថាយើងទៅខាងនេះចឹងទៅ ពេលយើងដកចឹងទៅយើងដាក់ការពារ អាគេអ្នកមកនៅហ្នឹងក៏ដាក់ៗទាំងអស់គ្នាៗ

ឈុនលី ៖ ពេលមីងមកនៅដីបួងហ្នឹង មានមីននៅ៧៩?

រ៉ុន ៖ កាលរត់មកដីបួងអត់មានទេ យើងរត់មកដីបួងអត់មីនទេ ដល់ពេលទ័ពនៅចេះដើរត្រៀមមានខ្សែត្រៀមមានអីគេដាក់ចឹងគេចេះដាក់មីន គេដឹកត្រង់សេរត្រៀមមកដាក់មីនៗ

ឈុនលី ៖ ចឹងអាខ្ទង់៨១ ៨២ហ្នឹងមីងនៅហ្នឹង គេអត់ទាន់ គេដាក់មីននៅ?

រ៉ុន ៖ ដាក់ហើយជំនាន់ហ្នឹងដាក់ហើយៗ

ឈុនលី ៖ ចឹងខ្ទង់៨០គត់?

វ៉ុន ៖ ចា៎!

ឈុនលី ៖ អាពេលដាក់ចឹង ប្រជាជនហ្នឹងមិនភ័យស្លាប់ហើយ?

វ៉ុន ៖ អូ! ជំនាន់ហ្នឹងត្រូវស្លាប់ច្រើនដែរហ្នឹង ស្លាប់ហ្នឹងផ្ទុះមីន ដាច់ជើងខ្ទាក់ភ្នែកខ្ទាក់អី មួយថ្ងៃៗ មិនដឹងស្អីៗ ។

ឈុនលី ៖ ចុះហេតុអីបានមីនទៅថៃ?

វ៉ុន ៖ គេដឹកទៅ ។

ឈុនលី ៖ ហេតុអីបានគេដឹកទៅ?

វ៉ុន ៖ ជំនាន់ហ្នឹងចុះយួនចូលមកនៅតាមហ្នឹង ចូលមកនៅតាមហ្នឹងទៅ គេដឹកយកទៅដាក់ស្រុកថៃ ។

ឈុនលី ៖ ៨៥?

វ៉ុន ៖ ចូល៨៥ ។

ឈុនលី ៖ មកវិញ៨៦?

វ៉ុន ៖ ៨៦ ៨៧នោះ ។

ឈុនលី ៖ ទៅនៅហ្នឹងទៅនៅជំរំអីគេ ឈ្មោះ៨៥?

វ៉ុន ៖ គេហៅជំរំ៨៥ហ្នឹងម៉ង ចា៎!ទៅនៅទឹកដីថៃគេហៅជំរំ៨៥ ។

ឈុនលី ៖ ទៅនៅហ្នឹងពិបាកទេ ជំរំ?

វ៉ុន ៖ អត់ពិបាកទេ នៅហ្នឹងដីថៃហ្នឹងអត់ពិបាកអីផង ។

ឈុនលី ៖ ប្រជាជនគេអី គេឲ្យយើងនៅដែរ?

វ៉ុន ៖ នៅពេញ ប្រជាជនថៃអត់អីទេ ចុះកន្លែងថាអង្គការយើងទិញដីនៅចឹងណា នៅច្រើនចុះ ប្រជាជនខ្មែរយើងច្រើនរាប់ពាន់រាប់ម៉ឺននាក់ ។

ឈុនលី ៖ ធ្វើផ្ទះនៅ ផ្ទះខ្ទម?

វ៉ុន ៖ ចា៎! ធ្វើផ្ទះប្រក់កៅស៊ូប្រក់អីនៅ ណាប្រូតស្បូវប្រូតអីក្រងប្រក់ឲ្យទៅ ។

ឈុនលី ៖ ហើយចឹងគេចិញ្ចឹមយើង គេឲ្យអីហូបចឹងទៅ?

វ៉ុន ៖ ចា៎! គេបើកគ្រប់មុខ ចុះឲ្យប្ដីទៅមុខទៅវ៉ៃ ឃើញប្ដីនេះចឹងគេបើកឲ្យគ្រប់មុខ ។

ឈុនលី ៖ ភ័យទេមីង ពេលប្ដីទៅចឹង?

វ៉ុន ៖ ហ៊ើ! ភ័យម្នាក់ៗណាមិនភ័យ ចង់ឲ្យបានផ្ដាច់ខ្លួនហ្នឹងអរចង់ស្លាប់ ឈប់វ៉ៃគ្នាហ្នឹងអរ អ្នកណាក៏ខ្លាច អ្នកណាក៏ភ័យមិនដឹងស្លាប់ថ្ងៃណា ។ ចុះនៅតែទៅនៅជំរំហ្នឹងឲ្យនៅតែស្រីៗ បើ

ប្ដីៗបញ្ជូនមកមុខអស់ចឹង មកវៀត្នាបញ្ជូនមកអស់ហើយ នៅតែអ្នកឈឺ នៅតែអ្នកធ្វើមិនកើតទេ ។

ឈុនលី ៖ មីងចុះអាខ្វង់៨៦ មីងមកវិញ ចុះ៨៧ ៨៨ ពេលមីងមកនៅហ្នឹងស្ថានភាពម៉េចទៅ?

រ៉ុន ៖ មកនៅតាមយើងមកនៅហ្នឹង អត់អីទេ នៅព្រំដែន ។

ឈុនលី ៖ តែមានមីនមានអីដដែល?

រ៉ុន ៖ មាន ប៉ុនដល់ហើយគេរកភាវគេមានដូចថាទំពក់គេ ។

ឈុនលី ៖ ស៊ីម៉ាក់អត់កាលហ្នឹង?

រ៉ុន ៖ កាលហ្នឹងអត់ទាន់មានស៊ីម៉ាក់ទេ ទើបមាននៅឡូវនេះហ្នឹង គេភាវតាមខ្លួនគេនេះ គេភាវតាមផ្ទះនេះចឹងណា ។

ឈុនលី ៖ អត់មានអង្គការណាផ្សេងទៀតមក?

រ៉ុន ៖ កាលហ្នឹង អត់ទេ មិនមែនអង្គការ ដូចពួកអ្នក កាលហ្នឹងពួកអ្នកស្ម័គ្រចុះភាវ ប៉ុនមិនមែនស៊ីម៉ាក់ផង ។ នេះស៊ីម៉ាក់ភាវឆ្នាំប៉ុន្មានហើយទេ ភាវត្រង់នេះ ។

ឈុនលី ៖ ៩០ដាង ២០០០ដាង?

រ៉ុន ៖ ដឹងឆ្នាំប៉ុន្មាន ទើបភាវ៣ឆ្នាំហើយកាលហ្នឹង ពេលស៊ីម៉ាក់មកភាវ យើងនៅយូរដែរ ។

ឈុនលី ៖ ៣ឆ្នាំ ២០០៧ហ្នឹង?

រ៉ុន ៖ ចា៎! ទើបភាវដែរ ឲ្យស៊ីម៉ាក់ភាវបានលែងសូវមានខ្វាចមីនខ្វាចអី ពីមុន ។

ឈុនលី ៖ ខ្ញុំឃើញកន្លែងនោះមួយ គេដាក់ចំការមីននោះ?

រ៉ុន ៖ ចា៎! កន្លែងខ្លះនៅអត់ទាន់ភាវអស់ នៅដូចថាដីនៅម៉ាប្អូនអីចឹងទៅ គេអត់ទាន់បានភាវគេដាក់ផ្លាក ដល់ពេលហើយគេហៅស៊ីម៉ាក់ភូមិអីគេធ្វើប្លង់ធ្វើអីចឹង គេហៅស៊ីម៉ាក់មកភាវ ឲ្យមើលត្រង់នេះទើបភាវហើយថ្ងៃមុននោះ ស៊ីម៉ាក់គេ ។

ឈុនលី ៖ អឺ! ម្ដុំនេះហ្នឹង?

រ៉ុន ៖ ចា៎! ភាវហើយដែរ ។

ឈុនលី ៖ ភាវបានច្រើនដែរ?

រ៉ុន ៖ ពីមុនអត់មានប៉ះទេ គេភាវដែលហើយណា ពីមុនគេភាវដែរ ប៉ុនដល់ពេលថាវាអត់ត្រូវប្លង់ស៊ីម៉ាក់ក្នុងស៊ីម៉ាក់ គេធ្វើការ ដល់ហើយគេឲ្យស៊ីម៉ាក់មកភាវទៀត ។ នេះទើបភាវហើយប្រហែលមុនភ្ជុំ ។

ឈុនលី ៖ តែអត់បានទេ?

រ៉ុន ៖ អត់មានអីទេ ដីនៅអស់ហើយហ្នឹង ប៉ុនត្រូវប្ដូរគេធ្វើការ គេចេះរាវ ។

ឈុនលី ៖ ចេះខ្លាច?

រ៉ុន ៖ ចាំ! ចេះប្រយ័ត្ន ។

ឈុនលី ៖ គេធ្វើការអី?

រ៉ុន ៖ ពួកស៊ីម៉ាក់ហ្នឹង ដែលពួកហ្នឹងគេត្រូវរាវ ដល់រាវអត់មានប៉ះអីផង ។

ឈុនលី ៖ ហើយអានេះគេអត់ទាន់មករាវទេ?

រ៉ុន ៖ ហ្នឹងឃើញគេដាក់ផ្លាកទៀត គេនៅរាវទៀតដឹង ។

ឈុនលី ៖ ហើយចុះមីង ចុះអាមុនពេលខ្មែរក្រហមផ្ដាច់ខ្លួនហ្នឹង ដូចមានសង្គ្រាមអីទៀត មានបាញ់គ្នាទៀត?

រ៉ុន ៖ អត់ៗ ។

ឈុនលី ៖ មានបាញ់គ្នាទៀតទេ?

រ៉ុន ៖ ជំនាន់ហ្នឹងអត់ ។

ឈុនលី ៖ អាមុនពេលផ្ដាច់ខ្លួនខ្ទង់៩០ជាង?

រ៉ុន ៖ អត់ទេ តាំងពីផ្ដាច់ហើយអត់អី បើមុនផ្ដាច់ហ្នឹងមានខ្មែរ ។

ឈុនលី ៖ ហ្នឹងអាមុនផ្ដាច់?

រ៉ុន ៖ អាមុនផ្ដាច់ អាខ្មែរនិងខ្មែរថាឈ្លោះគ្នាថថាជំនាន់ពួកប៉ៃលិន ហើយនឹងពួកហ្នឹងឈ្លោះគ្នា ។

ឈុនលី ៖ ម៉េចឈ្លោះគ្នា?

រ៉ុន ៖ មិនដឹងម៉េច ថាពួកស៊ុន សេន ជំនាន់ហ្នឹងឈ្លោះ ខ្ញុំអត់ ។

ឈុនលី ៖ ស៊ុន សេននៅខាងណា?

រ៉ុន ៖ ខ្មែរយើងហ្នឹង ។

ឈុនលី ៖ ប៉ុន្តែគាត់នៅខាងតំបន់ណា?

រ៉ុន ៖ កាលហ្នឹងនៅប៉ៃលិន ហ្នឹងថាវៃគ្នា ។

ឈុនលី ៖ ចុះក្រែងថាអៀង សារីនៅប៉ៃលិន?

រ៉ុន ៖ ចាំ! កាលហ្នឹងមិនគាហ្នឹង ហើយនឹងនេះនៅប៉ៃលិនទាំងអស់គ្នា ។

ឈុនលី ៖ ទៅឈ្លោះគ្នានៅហ្នឹង?

រ៉ុន ៖ ចាំ! ដែលពេលនេះហើយរកវៃនៅខាងហ្នឹងហើយ ពួកខ្ញុំអ្នកនៅហ្នឹងប្រុងរត់ទៅថៃ គេឲ្យត្រៀមខ្លួនប្រុងរត់ ។ ហើយព្ធថាត្រូវគ្នាវិញទៅ ។

ឈុនលី ៖ មីងចុះកាលមកនៅអ្នកណាគេចៅហ្វាយខេត្ត?

រ៉ុន ៖ នៅស្រុកម៉ាឡៃហ្នឹង កាលហ្នឹងពូនី ។

ឈុនលី ៖ ហ្នឹងគាត់ចៅហ្វាយស្រុក ដល់ពេលចៅហ្វាយខេត្តកាលពីមុន?

រ៉ុន ៖ អូ! ចៅហ្វាយខេត្តមិនដឹងពីណាទេ ខ្ញុំស្គាល់ពូនីចៅហ្វាយស្រុកម៉ាឡៃហ្នឹង ខេត្តមិនដឹងអ្នកណា អត់ស្គាល់គេ ។

ឈុនលី ៖ តែបើអ្នកគ្រប់គ្រងធំម៉ាតំបន់ហ្នឹង ដូចនៅប៉ៃលិនមានអៀង សារីអីចឹង ចុះដល់ពេលនៅម៉ាឡៃ អ្នកណាគេ?

រ៉ុន ៖ ម៉ាឡៃដឹងពីណាគេ ខ្ញុំអត់ស្គាល់ ។

ឈុនលី ៖ អត់ស្គាល់ដែរ?

រ៉ុន ៖ ចា៎! អត់ ។

ឈុនលី ៖ អត់សូវដឹង?

រ៉ុន ៖ ស្គាល់តែពូនី អស់សូវស្គាល់សូវដឹងនឹងគេ ។

ឈុនលី ៖ ចុះដល់ពេលមកពីជំរំ ។ ខ្ញុំសុំសួរបន្តិច ខ្ញុំចង់ដឹងអាពេលដែលមីងមកពីថៃវិញ ពេលហ្នឹងនៅតែទទួលជំនួយទៀត ទទួលស្បៀងទៀត?

រ៉ុន ៖ មកពីស្រុកថៃមកៗនៅត្រង់នេះ នៅទទួលអង្ករប្រហែលបានម៉ាឆ្នាំអីចឹង ដល់ផ្ដាច់ខ្លួនបានឈប់ម៉ង ។

ឈុនលី ៖ ផ្ដាច់ខ្លួនឆ្នាំណា៩០ប៉ុន្មាន?

រ៉ុន ៖ ៨៦ ៨៧ ៨០ ។

ឈុនលី ៖ ៩០ជាង ៩៥ ៩៦?

រ៉ុន ៖ ចា៎ៗ ៩០ យើងផ្ដាច់ខ្លួនឆ្នាំ ។

ឈុនលី ៖ ៩៦ ៩៧ ដូច៩៦?

រ៉ុន ៖ ផ្ដាច់ខ្លួនឆ្នាំប៉ុន្មានភ្លេចហើយ ដូចតាំង៩៦ហ្នឹងឯង ផ្ដាច់ខ្លួនគេឈប់បើកអីឲ្យហើយ ។

ឈុនលី ៖ ចឹងមុនផ្ដាច់ខ្លួនហ្នឹង នៅតែចឹង គេឲ្យអីចឹងទៀត គេឲ្យអង្ករឲ្យអី?

រ៉ុន ៖ អត់ ផ្ដាច់ខ្លួនហើយឈប់ម៉ង ។

ឈុនលី ៖ អត់ទេនិយាយថាអាមុនពេលផ្ដាច់ខ្លួន ដូចផ្ដាច់ខ្លួន៩៦ ដល់ពេលមុនផ្ដាច់ខ្លួនខ្ទង់៩៣ ៩៤ ៩៥ អាហ្នឹង?

រ៉ុន ៖ អាហ្នឹងនៅៗបើកដូចថាមានប្ដីធ្វើទ័ពធ្វើអីហ្នឹងគេបើក ។

ឈុនលី ៖ ហើយចុះដល់ពេលប្ដីមីងគាត់ធ្វើទ័ពធ្វើចឹង ខ្វង់ឆ្នាំហ្នឹងគាត់ធ្វើអី គាត់ទៅច្បាំងទៅអី?

វ៉ុន ៖ ទៅច្បាំងជាមួយគេនៅមុខហ្នឹង ។

ឈុនលី ៖ ទៅដល់ណាទៅ ច្បាំងដល់ណា?

វ៉ុន ៖ ទៅនៅម្ដុំស្វាយ ខាងលិចស្វាយខាងលិចអី ទៅម្ដុំអស់ហ្នឹងឯងនៅតាមវាលស្រែតាមនេះ គេហ្នឹងកន្លែងគេនៅហ្នឹង គេហៅកន្លែងស្អី តាមព្រៃ ។ នៅចឹង អាពេលយើងឈប់ច្បាំង ឈប់អីចឹង គេឲ្យចាប់ដីចាប់អីធ្វើដីស្រែដីអីយកហ្នឹង ។

ឈុនលី ៖ ហើយចុះមីងមានដឹងរឿងរ៉ាវថា កាលជំនាន់៣ឆ្នាំម៉ងម្ដុំនេះគេធ្វើអីគេ?

វ៉ុន ៖ អត់ដែលស្គាល់ ខ្ញុំកាល៣ឆ្នាំនៅខ្វង់ក្មេងនៅទីក្រុង អត់ដែលស្គាល់សោះ ។

ឈុនលី ៖ អត់ដែលឮគេនិយាយ?

វ៉ុន ៖ ចាំ! អត់ៗដែលស្គាល់រលីង ទើបស្គាល់មកនៅហ្នឹងម៉ង ។

ឈុនលី ៖ ចុះអ្នកស្រុកភូមិហ្នឹងអត់មានអ្នកណាដែលគាត់ធ្លាប់មកនៅ?

វ៉ុន ៖ ដែលអ្នកណាគេនៅស្រុកនេះទេ នេះសុទ្ធតែព្រៃម៉ង ជំនាន់ហ្នឹងបែបថៃនៅដឹងតាមអស់នេះ តាមមាត់អូរ ។

ឈុនលី ៖ ថៃនៅតាមមាត់អូរ ចឹងបានន័យថាអត់ចូលដីយើងផង?

វ៉ុន ៖ ចាំ!

ឈុនលី ៖ ចឹងបានន័យថាអត់ចូលដីយើងផងហ្នឹង?

វ៉ុន ៖ ហ្នឹងព្រំដែនត្រង់នេះឃើញសុទ្ធតែផ្ទះថ្មនេះអាតាមមាត់អូរយើង ខាងនោះមាត់អូរយើងហ្នឹង នោះខាងនោះអូរ ។

ឈុនលី ៖ .......កាលពីមុនដែរ?

វ៉ុន ៖ ចាំ! ឃើញសុទ្ធតែផ្ទះថ្មគេចាស់កាលពីមុននៅហ្នឹងឯងតាមអូរ ។

ឈុនលី ៖ ហើយដល់ពេលគេសមាហរណកម្មហ្នឹងទៅ ។ អូ!ចុះកាលជំនាន់បោះឆ្នោតនោះមីង បោះឆ្នោត៩២ ៩៣?

វ៉ុន ៖ បោះឆ្នោត ។

ឈុនលី ៖ អាហ្នឹងស្ថានភាពនៅនេះម៉េចទៅ?

វ៉ុន ៖ អត់អីទេ ជំនាន់បោះឆ្នោតហ្នឹងឯង ។

ឈុនលី ៖ យើងមានបោះឆ្នោតហ្នឹងគេអត់?

វ៉ុន ៖ បោះ អីណាជំនាន់កាលហ្នឹងតានីចៅហ្វាយស្រុក កាលបោះឆ្នោតដំបូង ។

ឈុនលី ៖ ចឹងខាងប្រជាជននៅនេះ គាត់អត់ទៅបោះឆ្នោតទេ?

ទូច ៖ អត់បោះទេ ៩៣ ។

ឈុនលី ៖ ម៉េចចឹងពូ?

ទូច ៖ បោះតែអ្នកក្នុងហ្នឹង ប៉ុននៅមិនទាន់ត្រូវយើង ។

ឈុនលី ៖ អូ! ត្រូវហើយយើងនៅនេះ ចាប់ពីស្រុកម៉ាឡៃមកតើពូ មានណាទៀត?

ទូច ៖ មកជំនៀវខ្មែរក្រហមទាំងអស់ កាលហ្នឹងអត់មានបោះឆ្នោត ៩៣អ៊ុនតាក់ ។

ឈុនលី ៖ ចា៎! អ៊ុនតាក់៩៣ ។

រ៉ុន ៖ គេផ្ដាច់ខ្លួនដែលយើងត្រូវគ្នាជាមួយនៅខាងក្នុងនៅប្រជាជនអស់នោះ បានយើងត្រូវគ្នាទៅ

ឈុនលី ៖ ហើយដល់ពេញបន្ទាប់ពីផ្ដាច់ខ្លួនមកយើងរស់នៅធម្មតា?

ទូច ៖ បាទ!

ឈុនលី ៖ រកស៊ីរកអីធម្មតា ។ ហើយបើតាមពូមើង ដែលរស់នៅបន្ទាប់ពីផ្ដាច់ខ្លួនចឹង រហូតមកដល់ឥឡូវចឹង ដូចថាយើងគិតថាស្ថានភាពមួយណាប្រសើរជាង?

រ៉ុន ៖ ឥឡូវហ្នឹងស្រួលហ្នឹងឯង រស់នៅចេះមិនមែនជិនាទន់មុនណា ជិនាទន់មុនយើងពិបាកខ្លាចងាប់ខ្លាចអី មិនបានដេកស្រួលទេ ។ ហើយយើងឥឡូវស្រួលមានពិបាកអី កូនទៅរៀនបានស៊ីស្រួល មានអីឲ្យកូនរៀនចេះ ។

ទូច ៖ អត់ចេះរកបានហូបឥឡូវហើយ ។

រ៉ុន ៖ ហ្នឹងហើយទៅរកបាន រកលុយបានសប្បាយហើយ យើងស្រុកយើងឥឡូវ ពីមុនមានអីដឹងថាព្រួយដឹងថាភ័យខ្លាច ។

ឈុនលី ៖ ចឹងមីងនៅសម័យខ្មែរក្រហមហ្នឹង មីងដែលធ្លាប់ជួយអ្នកណាម្នាក់ ធ្លាប់ជួយគេ?

រ៉ុន ៖ ថាអត់ ដឹងជួយម៉េច ។

ឈុនលី ៖ ចុះពូៗដែលជួយអ្នកណាគេ?

ទូច ៖ ជួយអី ។

ឈុនលី ៖ ពូនៅក្នុងសម័យខ្មែរក្រហមហ្នឹង ពូធ្វើទ័ពម៉ង?

ទូច ៖ បាទ!

ឈុនលី ៖ នៅណា?

ទូច ៖ នៅហ្នឹង នៅម៉ាឡៃហ្នឹង ។

ឈុនលី ៖ ចឹងពូអ្នកស្រុកកំណើតនៅហ្នឹង?

ទូច ៖ យើងនៅហ្នឹង ប៉ុន ។

រ៉ុន ៖ អត់ទេ គាត់នៅពោធិ៍សាត់ ។

ឈុនលី ៖ អ្នកពោធិ៍សាត់ដែរ?

ទូច ៖ បាទ! ប៉ុនខ្ញុំមកនៅព្រៃតាំងពីយូរហើយ តាំងពីសម័យអាពត ។

ឈុនលី ៖ ស្រុកកំណើត ស្រុកអីគេ?

ទូច ៖ នៅបឹងខ្នារ ។

ឈុនលី ៖ ឃុំបឹងខ្នារ ស្រុកបាកាន?

ទូច ៖ បាទ! ស្រុកបាកាន ។

ឈុនលី ៖ ពូដែលទៅលេងស្រុកទេ?

ទូច ៖ ទៅតើ ។

រ៉ុន ៖ ទៅជាប់ ។

ឈុនលី ៖ ខស្សរាហ៍ទៅដែរ?

ទូច ៖ បាទ! ទើបខានម៉ាសារហ្នឹងអត់បានទៅ ។

រ៉ុន ៖ ខែភ្ជុំអត់បានទៅលេងម៉ែ មុនៗទៅជាប់ មុនៗទៅជាប់ ។

ទូច ៖ ខែប្រូតឆ្នាំមុន ប្រូតហើយទៅ ។

ឈុនលី ៖ ចុះដូចពូធ្វើទ័ពចឹង ប្រហែលជាពូដឹងរឿងនៅនេះច្រើន ស្ថានភាពនៅនេះពិបាកៗខ្លាំង ពិបាកទ័ពជាងទ័ពនៅណាៗផ្សេងទៀត?

ទូច ៖ ហ៊ើ! មិនដល់ប៉ុ៉ាវ៉ាទេ វាពិបាកអាពេលយើងទៅសមរភូមិ ប្រយុទ្ធគ្នាតឹងតែង ។

ឈុនលី ៖ ចឹងពូថានៅស្រុកកំណើតនេះចឹង បានន័យថាក្នុងកំឡុងខ្មែរក្រហម ក្នុងរបបហ្នឹងម៉ង ពូនៅហ្នឹងម៉ង?

ទូច ៖ បាទ!

ឈុនលី ៖ ចឹងប្រជាជននៅនេះគាត់ធ្វើអី?

ទូច ៖ អត់មានទេ តាមនេះអត់មានប្រជាជនទេ ។

ឈុនលី ៖ មានសុទ្ធតែទ័ពម៉ង?

ទូច ៖ បាទ! មានទ័ពៗនៅនេះមុខភូមិ នេះពួកការពារព្រំដែនគេនៅ កន្លែងគេហៅផ្លូវចាស់គេ អាផ្លូវ៥០២ ។

ឈុនលី ៖ ចឹងពូនៅក្នុងទ័ពការពារព្រំដែនចឹង?

ទូច ៖ បាទ! ការពារព្រំដែន ៧៩ហ្នឹងនៅក្នុងព្រៃហ្នឹងហើយ ។

ឈុនលី ៖ ប៉ុន្តែអាខ្លួន៧៥ ៧៦ ៧៧?

ទូច ៖ ៧៥ ៧៦ នៅនិមិត្តនៅអីនោះ ។

ឈុនលី ៖ និមិត្តនៅណាទៅ?

ទូច ៖ កូនដីរ ប៉ោយប៉ែត ។

ឈុនលី ៖ បន្ទាយមានជ័យ ប៉ោយប៉ែត ។

ទូច ៖ ខ្ញុំនៅហ្នឹងឯង ។ ហើយដល់៧៩នៅនេះ នៅសាលាក្រៅយើង ជិតប៉ៃលិន ។

រ៉ុន ៖ ដើរនៅក្នុងព្រៃ គ្មានបានស្រួលទេ នៅតាមព្រៃ ។

ទូច ៖ នៅតាមហ្នឹងរហូតហ្នឹង ខ្មែរក្រហម ទៅនៅតាមភូមិបាន៤-៥ខែ មកព្រៃ គេដូរគ្នានោះ ដូរគ្នាមកធ្វើការ ។ នៅតាមនេះ គេថាខ្មែរសេរីៗហ្នឹងពួកប៉ារ៉ាហ្នឹងនៅ ។

ឈុនលី ៖ នៅម្តុំណាពូប៉ារ៉ាហ្នឹង?

ទូច ៖ នៅនោះ ស្រះខ្មែរសេរីនោះនៅមុខ ជិតភ្នំ ។

ឈុនលី ៖ ចុះពូខ្ញុំឮគេនិយាយថា នៅសម័យខ្មែរក្រហមគេឲ្យប្រជាជននៅស្រុកម៉ាឡៃ ទៅធ្វើអីគេ ទំនប់ស្អីគេ ម៉កហឹន?

ទូច ៖ អត់ទេ អត់មានធ្វើអី ៣ឆ្នាំ ទំនប់ខែដន ។

ឈុនលី ៖ ទំនប់ ម៉ក់ហឹន?

ទូច ៖ អឺ! កន្លែងទំនប់កាច់ហ្នឹង ។

រ៉ុន ៖ ពួកយើងមិនដែលទេ ។

ឈុនលី ៖ អាហ្នឹងខាងណាអ្នកធ្វើទេពូដឹង?

ទូច ៖ កាលសម័យ៣ឆ្នាំហ្នឹង ពួកកងចល័តហ្នឹង មានទាំងកងទ័ព ទាំងអីអស់ ។

ឈុនលី ៖ ប៉ុន្តែកាលហ្នឹងមានព្រៃ សុទ្ធតែព្រៃអត់?

ទូច ៖ ព្រៃដូចសព្វថ្ងៃ សព្វថ្ងៃវាលអត់ជាង មុនៗព្រៃច្រើន ។

ឈុនលី ៖ ប៉ុន្តែម៉ក់ហឹនហ្នឹងនៅណាទៅ?

ទូច ៖ ម៉ក់ហឹនអាផ្លូវទៅកូនដីរ ។

ឈុនលី ៖ នៅក្នុងឃុំអីគេ?

ទូច ៖ ឃុំទួលពង្រ ។

ឈុនលី ៖ កាលហ្នឹងប្រជាជនភាគច្រើនគេជម្លៀសមកពីណាវិញ?

ទូច ៖ ទេ! គ្មានប្រជាជនផង ។

វ៉ុន ៖ សុទ្ធតែអ្នកនៅទ័ព ។

ទូច ៖ អត់នៅទ័ពទេ ចូលព្រៃហ្នឹង ។

ឈុនលី ៖ អត់ទេ ចង់និយាយថាអ្នកណាអ្នកដឹកទំនប់ហ្នឹង ទ័ព ឬមួយ...?

ទូច ៖ ៣ឆ្នាំ ទ័ពផង ប្រជាជនផង គេឲ្យធ្វើរួមគ្នា កងចល័តគេហៅកងចល័ត ។

ឈុនលី ៖ ចឹងបានន័យថាអ្នកស្រុកនៅហ្នឹង អត់មានជម្លៀសទៅណាទេ ឲ្យនៅហ្នឹងធ្វើការនៅហ្នឹង បណ្ដោយ?

ទូច ៖ អត់ទេ បាទ!នៅហ្នឹង ។

ឈុនលី ៖ ហើយពូអត់ដែលទៅហ្នឹងទេ?

ទូច ៖ ទេ! ខ្ញុំនៅលើកនៅមើលហ្នឹងគេហ្នឹងឯង ។

ឈុនលី ៖ មកលើកទំនប់ហ្នឹងដែរ?

ទូច ៖ បាទ! បាន ទំនប់ខៃដន ទំនប់អីហ្នឹងខ្ញុំបានលើកទាំងអស់ ។

ឈុនលី ៖ ខៃដននៅណាវិញ?

ទូច ៖ ខៃដនអាយាង ផ្លូវពីយាងមក ។

វ៉ុន ៖ អាផ្លូវទៅឯយាងមក ផ្លូវទៅចេះទៅប៉ោយប៉ែតហ្នឹង ។

ទូច ៖ ទៅទំនប់ប៉ុនណាណៃ ដែលទៅប៉ោយប៉ែតអត់?

ឈុនលី ៖ អត់ដែរផង?

ទូច ៖ អូអត់ដែល ពិបាកដែរ ។

វ៉ុន ៖ អាផ្លូវទៅយាង អាខ្នងយើងទៅចេះ ហួសខ្វាងកាប់ទៅចេះទៅផ្លូវចូលទៅប៉ោយប៉ែត ។

ឈុនលី ៖ ចុះពូធ្លាប់ទៅលើកទំនប់ទាំងពីរហ្នឹង ម៉ក់ហឺនក៏ទៅ?

ទូច ៖ បាទ! ខ្ញុំលើក បានលើក ។

ឈុនលី ៖ ចុះអាម៉ក់ហឺនហ្នឹងជំរៅប៉ុន្មានម៉ែត្រទៅ?

ទូច ៖ ទេ! មិនជ្រៅណាភក់ មិនមែនទំនប់គេទេ ។

ឈុនលី ៖ ប្រឡាយ?

ទូច ៖ លើកប្រឡាយគេទៅ ។

ឈុនលី ៖ ចុះអាទំនប់មួយទៀតនោះ?

ទូច ៖ ទំនប់នោះបានធំ ទំនប់ខែដន ប៉ុនបាក់អស់ហើយ ឥឡូវមានណា ។

ឈុនលី ៖ កាលហ្នឹងគេលើកទំនប់ដើម្បីធ្វើអីគេ?

ទូច ៖ យកទឹកធ្វើស្រែ ។

ឈុនលី ៖ ធ្វើស្រែនៅម្តុំស្រុកហ្នឹងទៅ?

ទូច ៖ បាទ! នៅម្តុំកូនដីរ ពេលវាលស្រែស្រូវពេញហ្នឹង ខែប្រាំងខែវស្សា នេះមានទ្វារទឹកគេអីហ្នឹង ឥឡូវហ្នឹងបិទទ្វារទឹកហើយលិចដើមងាប់ អស់ស្រូវអស់រលីង លិចស្រូវអស់ ។

ឈុនលី ៖ ពេលខ្ញុំមកលិចតាមផ្លូវ លិចទឹកដាច់ផ្លូវទៀត ។

ទូច ៖ បាទ! វានេះហ្នឹងវាដាប់........វាបិទៗចោល ។

វ៉ុន ៖ ខែវស្សាគេអត់បើក ។

ទូច ៖ បើកអីរួច បើបិទទឹកដាច់ម៉ង បិទចោលអស់ បិទយកទឹកយកជ្រុល អាហ្នឹងងាប់អស់ លិចអស់ ។

ឈុនលី ៖ ចុះពូកាលពូធ្វើទ័ពហ្នឹង អ្នកណាអ្នកដឹកនាំទ័ពនៅនេះ នៅតំបន់ម៉ាខ្សែ?

ទូច ៖ ហ៎! មេចំរុះគ្នា ម្តងនេះម្តងអានោះ ។

ឈុនលី ៖ ពូចាំៗឈ្មោះទេ?

ទូច ៖ អត់ទេ ភ្លេចអស់ហើយ យូរហើយតាំងពី៧៧ ៧៨ ។ មេដូរគ្នាគ្រប់ៗគ្នាម្តងទៅនេះ ម្តងទៅនោះ ។

ឈុនលី ៖ ចុះដល់ពេលឆ្នាំ៩០ជាងអីហើយ?

ទូច ៖ ៩០ជាងមកយើងនេះ ។

ឈុនលី ៖ ៨០ ៩០ៗ?

ទូច ៖ អាហ្នឹង៧៩ មករហូតដល់នេះមក ។

ឈុនលី ៖ អ្នកណាអ្នកកាន់ទ័ពទៅពូ?

ទូច ៖ ទ័ពនៅនេះៗ ។

ឈុនលី ៖ តានីហ្នឹងក្រែងជាចៅហ្វាយស្រុក?

ទូច ៖ កងពលតាភាព តាអី ។

ឈុនលី ៖ តាភាព អាហ្នឹងគេហៅមេចទៅ ប្រធានកងពល?

ទូច ៖ សុខ ភាព កងពល ។

ឈុនលី ៖ មេកងពល?

ទូច ៖ បាទ!

ឈុនលី ៖ ត្រកូលអីគេទៅពូ?

ទូច ៖ សុខ ភាពហ្នឹង ។

ឈុនលី ៖ សុខ ភាព?

ទូច ៖ បាទ! ផ្កាយ៣ ។

ឈុនលី ៖ ផ្កាយ៣ពីអន្កាល់ ឥឡូវហ្នឹង?

ទូច ៖ ឥឡូវហ្នឹង ។

ឈុនលី ៖ នៅណា?

ទូច ៖ នៅជាមួយសម្តេចនាយកហ្នឹង ។

ឈុនលី ៖ នៅភ្នំពេញទេ?

ទូច ៖ បាទ!

ឈុនលី ៖ អូ! មេកងពលប៉ុន្មានទៅ កងពលលេខអី?

ទូច ៖ កងពល៤៥០ ។

ឈុនលី ៖ ៤៥០ ទីតាំងនៅណា?

ទូច ៖ នៅយើងម៉ាខ្មែ ។

ឈុនលី ៖ នៅស្រុកម៉ង?

ទូច ៖ បាទ!

រ៉ុន ៖ ប្រពន្ធគាត់នៅម៉ក់ហឹន នៅ ផ្ទះនៅនៅគ្រប់កន្លែង ផ្ទះគាត់ ប្រពន្ធគាត់ នៅស្វាយក៏មាន ។

ទូច ៖ សព្វថ្ងៃ....ដឹងគេនៅណា ។

ឈុនលី ៖ ចុះក្រៅពីឈ្មោះសុខ ភាពហ្នឹង អ្នកណាគេទៀត?

ទូច ៖ អឺ! តច្រើនណាស់ ។

ឈុនលី ៖ ចុះក្រៅពីឈ្មោះសុខ ភាពហ្នឹង អ្នកណាគេទៀត?

ទូច ៖ អឺ! តច្រើនណាស់ មានស្ទីផុន ម៉ោង ណាខ្លះ ចៀម ។

ឈុនលី ៖ គាត់ផ្លាស់ប្តូរគ្នា?

ទូច ៖ ទេ! រងតៗ ។

ឈុនលី ៖ រងហ្នឹងឈ្មោះអី ពូចាំទេ ខ្ញុំចង់?

ទូច ៖ អត់ចាំនាមត្រកូលគាត់ មានផុន មានមោង មានណា ពូចៀម

ឈុនលី ៖ ផុនៗហ្នឹងគាត់ម៉េចទៅអនុ?

ទូច ៖ បាទ!

ឈុនលី ៖ ដល់ពេលចៀមហ្នឹងនោះ?

ទូច ៖ សុទ្ធតែមកក្រោយៗហ្នឹងតៗគ្នា សមាជិកជីងផ្នែកស្អីៗគេ ខ្ញុំភ្លេចអស់ហើយ យូរហើយ .........។

រ៉ុន ៖ រាល់ថ្ងៃretireអស់ហើយ។

ទូច ៖ ចាស់ៗអស់។

ឈុនលី ៖ ផុនហ្នឹងគាត់នៅណា?

ទូច ៖ នៅ៩៣។

រ៉ុន ៖ គាត់ចាស់ៗអស់ហើយ រាល់ថ្ងៃ គាត់លែងធ្វើអី។

ទូច ៖ កាលមុនគាត់នៅភូមិភាគ។

រ៉ុន ៖ ពីមុនគាត់ចេះនៅធ្វើកើត តែឥឡូវឈឺ។

ឈុនលី ៖ រាល់ថ្ងៃនៅខាងភូមិភាគ?

ទូច ៖ បាទ!

ឈុនលី ៖ ប្រធានភូមិភាគ?

ទូច ៖ អត់ទេ ប្រធាន.....។

ឈុនលី ៖ គេហៅម៉េច?

រ៉ុន ៖ នោកន្លែងភូមិភាគ គេយកដាក់កន្លែងភូមិភាគ ក្រៅពីហ្នឹងជីងណាធ្វើអីណាណែសព្វថ្ងៃ មិនដែលហ្នឹងជួបផង។ ខ្លះគេនៅផ្ទះអត់នៅធ្វើអី។

ឈុនលី ៖ ចាស់ៗអស់ហើយ។

រ៉ុន ៖ ចាស់អស់ហើយ។

ទូច ៖ គាត់ចាស់.........។

ឈុនលី ៖ ឯកឧត្តមហើយ?

ទូច ៖ បាទ! អឺ!សុខភាពៗ ស្តាប់តែទូរទស្សន៍ជីង។

រ៉ុន ៖ ក្នុងទូរទស្សន៍អត់ដែលសូវឃើញគាត់។

ទូច ៖ គាត់ពួកម៉ាក់ជាមួយហុក ឡង់ឌីហ្នឹង។

ឈុនលី ៖ អូ! ខ្សែធំ?

វ៉ុន ៖ បាទ! ពួកម៉ាក់គាត់ហុក ឡុងឌី ។

ឈុនលី ៖ តាមពិតសុខ ភាពហ្នឹង គាត់អ្នកស្រុកណា?

ទូច ៖ កំពង់ឆ្នាំង ។

វ៉ុន ៖ ....នៅកំពង់ឆ្នាំង ។

ឈុនលី ៖ ដើមកំណើតកំពង់ឆ្នាំង?

ទូច ៖ .................... ។

ឈុនលី ៖ សុខ ភាព ដូចធ្លាប់ឮថ្ងៃមុន?

ទូច ៖ មាឌខ្មៅ មាឌធំ ។

វ៉ុន ៖ មានខ្មៅគិល មាឌថាដូចអាមេរិចចឹង មាឌគាត់ធំណាស់ ។

ទូច ៖ ២ម៉ែត្រ កំពស់គាត់ ហើយមាឌគាត់ដល់ ។

ឈុនលី ៖ ហើយចឹងបានកាន់ខាងទ័ពសម?

ទូច ៖ បាទ! កាចណាស់គាត់ហ្នឹង តឹងតែង មិនកាចអី តែនិយាយខុស ។

វ៉ុន ៖ បានតែមាត់ជាមួយអ្នកខុស ។

ទូច ៖ រឿងហួបចុកអី..... ។

វ៉ុន ៖ មាឌគាត់ដូចអាមេរិច មាឌឡើងដំបង ខ្ពស់ ។

ទូច ៖ ខ្ពស់ តែខ្មៅ ម្ដាយគាត់អីមកស្លាប់នៅហ្នឹងយើងនេះ ស្លាប់នៅម៉ាឡៃ ធ្វើបុណ្យ ។

វ៉ុន ៖ នៅវត្ត៩៣ ។

ឈុនលី ៖ ចុះពូចេញពីស្រុកកំណើតហ្នឹងតាំងពីឆ្នាំណា?

ទូច ៖ ខ្ញុំ ។

ឈុនលី ៖ ចូលធ្វើទាហាននោះ?

ទូច ៖ តាំងពីឆ្នាំ៧៣នោះ ។

ឈុនលី ៖ ចូលធ្វើទាហានឆ្នាំ៧៣?

ទូច ៖ បាទ! ធ្វើខ្មែរក្រហមតាំងពីឆ្នាំ៧៣ ។

ឈុនលី ៖ ធ្វើនៅណា?

ទូច ៖ នៅប៉ៃលិន អឺ!នែក!នៅបាត់ដំបង កោះក្រឡ ។

ឈុនលី ៖ ចឹងពេលមកនៅកោះក្រឡ?

ទូច ៖ បាទ! នៅព្រៃរហូតតាំងពី៧៣រហូតទាល់តែ?

ឈុនលី ៖ ទាល់តែសមាហរណកម្មហ្នឹង?

ទូច ៖ ទាល់តែសម័យ៣ បាទ!ហ្នឹងបាននៅស្គាល់ផ្ទះ មុនមិនដែលស្គាល់ទេ។

រ៉ុន ៖ ផ្ទះទើបបានទៅលេងឥឡូវ បើខ្ញុំអត់សោះ។

ទូច ៖ តែផ្ទះមិនដឹងណាៗមុខណាណែវង្វេងអស់ហើយ។

រ៉ុន ៖ ផ្ទះទើបបានទៅលេងឥឡូវ។

ទូច ៖ តែផ្ទះមិនដឹងទៅណាមុខទៅណាទៅណែ ភូមិណាវង្វេងអស់ ចុះមកតាំងពីតូច៣០ឆ្នាំ។

រ៉ុន ៖ បើខ្ញុំអត់សោះទៅស្រុករលីង។

ឈុនលី ៖ ចុះដូចពូនៅទ័ពចិន នៅកោះក្រឡហ្នឹង អាហ្នឹងវៃជាមួយអ្នកណាគេ?

ទូច ៖ វៃជាមួយអាមេរិច។

ឈុនលី ៖ ៧៣ លន់ នល់?

ទូច ៖ លន់ នល់។

ឈុនលី ៖ ចុះដល់ពេល៧៥ភ្លាមមកខាង?

ទូច ៖ ៧៥ ខ្ញុំមកតាមព្រៃ មកនៅប៉ោយប៉ែត ជាយដែន ប៉ុននៅខាងជើង។

ឈុនលី ៖ បងប្អូនប៉ុន្មាននាក់ទៅពូ?

ទូច ៖ បងប្អូនខ្ញុំច្រើន ៩នាក់។

ឈុនលី ៖ នៅណានោះគាត់?

ទូច ៖ នៅឯស្រុកនោះ។

ឈុនលី ៖ ចិនមានតែពូទេ មកនេះតែឯង?

ទូច ៖ មកតែខ្ញុំតែឯង។

ឈុនលី ៖ ចុះពីដំបូងហេតុអីបានពូចូលធ្វើទាហានចិន?

ទូច ៖ អឺ! ពុកខ្ញុំមកធ្វើខ្មែរក្រហម ខ្ញុំមិនតាម។

ឈុនលី ៖ អូ! ចិនគាត់ទ័ពដែរចឹង?

ទូច ៖ បាទ!

ឈុនលី ៖ បើចិនពូមកហ្នឹងមកជាមួយឪពុក?

ទូច ៖ មកជាមួយពុកខ្ញុំ។

ឈុនលី ៖ ចិនម្ដាយ ហើយបងប្អូននៅហ្នឹងទៅ?

ទូច ៖ នៅស្រុកទៅ បើថាឪពុកខ្ញុំទៅផ្ទះវិញ ខ្ញុំមកគាត់ទៅផ្ទះវិញ។

ឈុនលី ៖ អាពេលផ្ដាច់ខ្លួនហ្នឹង?

ទូច ៖ អត់ទេ គាំងពីវើលន់ នល់នោះ ។

ឈុនលី ៖ វើលន់ នល់ចប់គាត់ទៅផ្ទះវិញ?

ទូច ៖ អត់ទេ មិនទាន់ចប់ផងគាត់ទៅ ។

ឈុនលី ៖ ហើយពូនៅនេះទៅ?

ទូច ៖ ខ្ញុំក៏នៅហ្នឹងរហូត ។

ឈុនលី ៖ គាត់របៀបទ័ពធម្មតាដែរ?

ទូច ៖ បាទ! ទ័ព ។

ឈុនលី ៖ មិនមែនមេអីគេ?

ទូច ៖ អត់ទេ សាមញ្ញ កូនទាហាន ។

ឈុនលី ៖ កូនទាហាន ដល់ពេលកូនប្រុសតាមឪពុកទៅទាហាន?

ទូច ៖ ហើយខ្ញុំកូនបងគេបង្អស់ ។

ឈុនលី ៖ កាលហ្នឹងអាយុប៉ុន្មាន ពូ?

ទូច ៖ អាយុប៉ុន្មានដណ្ដប់ឆ្នាំ ១៣ ១៤ឆ្នាំ មក ។

ឈុនលី ៖ ចុះឥឡូវពូអាយុប៉ុន្មាន?

ទូច ៖ ៥០ជាង ។

រ៉ុន ៖ ៥១ ៥២ ។

ទូច ៖ ៥២ ៥៣ហើយ ។

ឈុនលី ៖ ចុះឈ្មោះពូ ដាក់ឈ្មោះចឹងតាំងពីយូរមកហើយដាក់ឈ្មោះ តូចចឹងម៉ង?

ទូច ៖ បាទ!

ឈុនលី ៖ នៅក្នុងព្រៃរហូត?

រ៉ុន ៖ មិនដែលបាននៅស្រុកស្រួលហ្នឹងគេ ទើបបានស្រួលយើងឥឡូវ ។

ឈុនលី ៖ ៩៦?

ទូច ៖ បានសម័យឥឡូវហ្នឹង ។

ឈុនលី ៖ ចឹងទើបបានប៉ុន្មានឆ្នាំនេះ ២០ឆ្នាំ?

ទូច ៖ បាទ!

រ៉ុន : ចា៎! មិនដែលបានស្រួលទេ យើងផ្តាច់ខ្លួនហើយ បានទៅលេងផ្ទះលេងអីចឹងបាននៅស្រួល ។

ទូច : ដើរលេងដើរអី ។

រ៉ុន : ដើរលេងនេះនោះ ។

ទូច : មិនដែលស្គាល់ទេ ពីមុនឮថាភ្នំពេញៗមិនដឹងភ្នំពេញមុខទៅណាផង ពីដើម ។

រ៉ុន : មិនដែលបានស្គាល់ដើរលេងតាមទីក្រុងអី អត់រលីងទើបស្គាល់ឥឡូវហ្នឹង ។

ទូច : ........មិនដែលបានទៅណាផង ។

ឈុនលី : ចុះពូពេលចូលធ្វើទ័ពជំបូងចឹង ពិបាកទេ?

ទូច : ពិបាក ។

ឈុនលី : គេធ្វើបាបអត់?

ទូច : អត់ទេ ។

រ៉ុន : គេធ្វើបាបអីនៅទ័ព យើងដេកតាមព្រៃតាមអី ។

ទូច : គ្រាន់តែពិបាកអត់អីហូប ។

ឈុនលី : អត់អីហូប?

ទូច : បាទ!

ឈុនលី : ហើយចឹងបានអីទៅ?

ទូច : ចុះមានពេលមានពេលអត់ ហើយយើងហៅតស៊ូ ។

ឈុនលី : មានពេលដាច់បាយដែរ?

ទូច : បាទ! យីដាច់ម៉ាអាទិត្យអីនោះ ជួនកាលកន្លះខែ ខ្លះយើងបើបានបបរក៏ដាច់គ្មានអីបបរ ដើរបេះអានេះបេះនោះហូបតាមព្រៃ ផ្លែឈើផ្លែអី ។ ចឹងបានថាខ្មែរក្រហមស៊ីស្វិកខ្ចីង ។

ឈុនលី : ពូចុះពូធ្វើតាំងពី៧៣ ដល់ពេលចប់លន់ នល់ ៧៥បានសម្តេចឪឲ្យចូលស្រុកនោះ អឺ!ឲ្យចូលព្រៃ សម្តេចឪប្រកាសឲ្យចូលព្រៃ?

ទូច : ហ៎! អាហ្នឹងតាំងពីសម័យលន់ នល់ហ្នឹងហើយចូលព្រៃ.....។

ឈុនលី : ចឹងពេលពូចូល៧៣ហ្នឹងដោយសារតែសម្តេចប្រកាសហ្នឹង?

ទូច : ទេ! សង្គ្រាមកើតហើយ ចូលហ្នឹង ចុះសង្គ្រាមកើតតាំងពីមុន៧៣ សង្គ្រាមលន់ នល់តាំងពី៧១ លន់ នល់ ។

ឈុនលី : ៧០គត់ដល់៧៥?

ទូច ៖ អូ! ៧០គត់ហ្នឹងហើយ ។

ឈុនលី ៖ ចុះដល់ពេលសម្ដេចប្រកាសឲ្យចូលព្រៃចូលអីហ្នឹង អាហ្នឹងពូចូលស្រុកហើយហ្នឹង?

ទូច ៖ ចូល គាត់ប្រកាសហើយមុនហ្នឹងទៀត ថាឲ្យចូលព្រៃ ឲ្យតស៊ូ ។

ឈុនលី ៖ ចឹងគោលបំណងរបស់ពូ ហើយនឹងឪពុករបស់ពូ ដែលគាត់ធ្វើទាហានហ្នឹងដោយសារ តែគាត់ស្រឡាញ់សម្ដេចចឹង?

ទូច ៖ ហ្នឹងហើយ ។

ឈុនលី ៖ ចង់ឲ្យសម្ដេចចូលស្រុកវិញ?

ទូច ៖ បាទ! អឺ ។

ឈុនលី ៖ រហូតទៅ ។ ហើយដល់ពេលក្រោយសមាហរណកម្មចឹងទៅ ពូនៅធ្វើទ័ពទៀតអត់?

ទូច ៖ អត់ទេ ឈប់ ។

ឈុនលី ៖ ឈប់ពេលហ្នឹងម៉ង?

ទូច ៖ បាទ! ឈប់មុនទៀតខ្ញុំ ឈប់តាំងពីឆ្នាំ៩៨ ។

ឈុនលី ៖ ពូបានទៅថៃអត់ ទៅជាមួយមីងដែរ?

រ៉ុន ៖ យើងនៅស្រុកថៃ គេដឹកទៅ ។

ទូច ៖ អូ! ទៅតើ ៨៥ ។

ឈុនលី ៖ ទៅហើយមីងថាស្រីៗនៅទៅ ប្រុសៗមកច្បាំង?

ទូច ៖ ទៅមុខហ្នឹងហើយ ប្រុសៗទៅច្បាំងចឹងទៅ បានទៅលេងស្រីៗហ្នឹងឲ្យទៅលេង៨-១០ ថ្ងៃ ។

រ៉ុន ៖ ឲ្យជួបប្រពន្ធ អាពេលប្រពន្ធឈឺ ហើយកូនឈឺចឹង គេឲ្យប្ដីទៅហើយណា តែឈឺ អត់ឈឺចឹងមកនៅតាមព្រៃមុខៗនេះឯង គេហៅមកមុខ ។

ទូច ៖ ម៉ាឆ្នាំទៅផ្ទះបានម៉ាខែ យូរហើយ ។

រ៉ុន ៖ ថាយើងសម្រាលកូនហើយ៣ខែចឹង ប្ដីមកមុខបាត់ ទាល់តែកូនចេះដើរចេះនិយាយហើយ បាន កូនខ្ញុំអាបងអាទី២អត់ស្គាល់ឪវាទេ កូនទៅធំកូនដើរលេងបាត់ៗ ឪវាទៅមុខទៅវ៉ៃអីចឹងបាត់ទៅវិញអត់ស្គាល់ ទៅលេងកូនៗហៅពូហៅអីបែកយូរពេក ។

ទូច ៖ វាអត់ស្គាល់ ។

រ៉ុន ៖ វេទនាណាស់នៅ ជំនាន់ហ្នឹង ចិញ្ចឹមកូន ។

ឈុនលី ៖ ចឹងបានន័យថាមកដល់សម័យឥឡូវហ្នឹង មីងមានអារម្មណ៍ម៉េចទៅ?

រ៉ុន ៖ សប្បាយណាស់ អត់ដូចមុនទេ ខ្ញុំសប្បាយ រាល់ថ្ងៃនៅបានស្រួល ពិបាករកលុយរកអីបានចាយ សប្បាយម៉ង អត់ដូចមុនទេ ។

ទូច ៖ ពិបាកតែរឿងរកលុយចាយមិនបាន ។

រ៉ុន ៖ ចាំ! គ្រាន់ថាពិបាកម៉ាផ្លូវរកលុយមិនបានចាយ ថាបានមានលុយចាយហើយសប្បាយចិត្តណាស់ ។ អត់ពិបាកដូចមុន ខ្ញុំមុនពិបាកណាស់ ពិបាកកូនឈឺ កូនអត់អីហូបរាល់ថ្ងៃសប្បាយ ។

ឈុនលី ៖ ចុះមីងពូមានសល់រូបថតចាស់ៗ?

រ៉ុន ៖ អត់រលីង ខ្ញុំ ។

ទូច ៖ ពីដើមថតផង មានអីហ្នឹងថតសម័យនោះ ។

ឈុនលី ៖ ទ័ពយើងអត់ដែលថតរូប?

ទូច ៖ អត់ទេ ។

រ៉ុន ៖ អត់គេអត់ដែលមានអីថតឲ្យផង ។

ទូច ៖ អារឿងថតកាលសម័យឆ្នាំ៨៦ ៨៧មាន មិនដឹងទៅណាអស់ ថតកាល....។

ឈុនលី ៖ ៨០ជាងនៅសល់ដែរ តែអស់ហើយឥឡូវ?

ទូច ៖ អស់ មិនដឹងគេយកទៅណា គេយកទៅណាអស់ហើយ ខ្ញុំចេះថត កាលហ្នឹងមានអាប់ប្រៃមានអីទិញឲ្យទៅមុខឲ្យចេះថតៗ ថតគេវៃគ្នា ។

ឈុនលី ៖ អាហ្នឹងសខ្មៅ?

ទូច ៖ អត់ទេ ។

ឈុនលី ៖ កូល័រ?

ទូច ៖ ខ្ញុំយកមកដល់ផ្ទះ យកមក....។

ឈុនលី ៖ ឥឡូវបាត់អស់រលីង ស្តាយណាស់រូបថតអស់ហ្នឹង?

ទូច ៖ គេសុំ មិនដឹងសុំយកទៅណា ។

រ៉ុន ៖ អត់ទេ ច្រើនដួបបងប្អូន គេចេះសុំយកទៅមើលបែកគ្នាយូរៗ ពេលជួបចឹងយកទៅ ។

ទូច ៖ ច្រើនអ្នកស្គាល់គ្នា ។

រ៉ុន ៖ អាថតវង់ៗជួបម៉ែជួបឪយកទៅអស់ហើយ យកទៅទុកស្រុកអស់ហើយ សល់យើងថតថ្មីឥឡូវនេះមានអី កាលជំនាន់ហ្នឹងអស់រលីងមកនៅក្មេងៗ ។

ឈុនលី ៖ ចុះពូធ្វើទ័ពចឹង ពេលមុនផ្ដាច់ខ្លួនចឹង ពូមានដែលគិតថាចង់ចូលមកជាមួយរដ្ឋាភិបាលមុនគេ អីចឹង ដែរអត់?

ទូច ៖ ទេ! អារឿងចិត្តចេះចង់ តែយើងមិនដឹងធ្វើម៉េច ។

ឈុនលី ៖ ចឹងបានន័យថាពូអត់ចង់ធ្វើខ្មែរក្រហមទេ?

ទូច ៖ ចេះមានគំនិតចង់ទៅ ប៉ុនតើ ។

រ៉ុន ៖ អត់ចង់ទេ គំនិតចង់ អត់ចង់ធ្វើម៉ង រឿងវ៉ៃអត់ចង់សោះ ប៉ុនមិនដឹងធ្វើម៉េចមិនហ៊ាន ទោះបីយើងរត់ទៅនៅខាងនោះអត់ហ៊ាន ។

ទូច ៖ គេឃោសនា ហ្នឹងការឃោសនាខាងណាហើយទៅខាងហ្នឹងហើយ ដល់យើងទៅតែយើង ទៅខ្លាច ។

រ៉ុន ៖ គេចាប់ ។

ទូច ៖ គេចាប់ ។

រ៉ុន ៖ គេវ៉ៃយើងចោល ។

ឈុនលី ៖ អាហ្នឹងយើងម្នាក់ឯង?

ទូច ៖ យើងម្នាក់ឯង

រ៉ុន ៖ ចាំមើលខ្ញុំទៅនៅខាងឃុំខាងភូមិអីចឹង គេរកមុខរកសឹងអី ។

ឈុនលី ៖ ខាងណា?

ទូច ៖ ខ្ញុំទៅនៅប៉ុន្មានឆ្នាំ ។

រ៉ុន ៖ គាត់ទៅនៅទ័ពរត់ទ័ព រត់ទៅនៅមុនហ្នឹង៣ឆ្នាំ ៤ឆ្នាំ ហើយគេរកមុខ គេមករករឿងខ្ញុំនៅ ផ្ទះនេះ ។

ឈុនលី ៖ អ្នកណាគេមករករឿង?

ទូច ៖ មេៗខ្មែរក្រហម ។

រ៉ុន ៖ មេគេ ដូចប្ដីខ្ញុំទៅបាត់អីចឹង គេសួរថាប្ដីខ្ញុំទៅធ្វើទៅស៊ើបការណ៍ប្ដីខ្ញុំទៅយកការណ៍យកអី នោះ ។

ឈុនលី ៖ គេខ្លាចយើងចូលនៅនោះ?

រ៉ុន ៖ ចាំ! គេមករករឿងខ្ញុំនៅផ្ទះហ្នឹង ខ្ញុំកាលហ្នឹង......... ។

ទូច ៖ ........ចូលកន្លែងអ៊ុនតាក់ ខ្ញុំនៅតែក្នុងហ្នឹង កាលអ៊ុនតាក់ គេវ៉ៃគ្នាមិនទាន់បានចេញមក វិញ ផងនៅតាមភូមិ ។

វ៉ុន ៖ នៅម្តុំចំណោម គាត់នៅតាមភូមិគេហ្នឹង ។

ទូច ៖ ហើយទាហានវ៉ៃខ្មែរក្រហមនៅនេះ ប៉ុនខ្ញុំនៅជាមួយវាហ្នឹង នៅជាមួយទាហានហ្នឹង ដល់ពេលវាវ៉ៃៗអាអ្នកនៅឯនេះទៅ ដល់ខ្ញុំនៅនោះអត់អី ។

វ៉ុន ៖ គាត់នៅធ្វើទ័ពខ្មែរក្រហមមែន តែត្រូវគ្នាជាមួយគេខាងនោះ គាត់នៅត្រូវគ្នាជាមួយបងប្អូនយើងខាងហ្នឹងមិនអត់អីហូប យើងធ្វើចឹង បងប្អូនគេស្រឡាញ់គាត់ណាស់ ។ គេមករករឿងប្រពន្ធនៅផ្ទះនេះ ហើយប្តីខ្ញុំទៅនៅធ្វើស្អីៗនៅ ។ យី!ទម្រាំបានសុខស្រួលខ្ញុំពិបាក ។

ឈុនលី ៖ គេមកតាមរក?

វ៉ុន ៖ ចា៎! និយាយពីយប់ដេកយាម ។

ឈុនលី ៖ អ្នកណាអ្នកមីងស្គាល់ឈ្មោះ?

វ៉ុន ៖ អ្នកនៅក្នុងកន្លែង ក្នុងកងគាត់ហ្នឹង ទម្រាំបានសុខស្រួលខ្ញុំពិបាកណាស់ និយាយពីយប់ឡើងសុទ្ធតែដេកយាម ។

ឈុនលី ៖ អ្នកណាអ្នកមកហ្នឹង មីងស្គាល់ឈ្មោះអត់?

វ៉ុន ៖ ពួកអ្នកនៅក្នុងកន្លែងក្នុងកងគាត់ ដែលនៅទ័ពជាមួយគាត់ហ្នឹង ដូចថានៅកងជាមួយ ។

ឈុនលី ៖ មេៗ?

វ៉ុន ៖ ចា៎!

ឈុនលី ៖ ឈ្មោះអីគេមេហ្នឹង?

វ៉ុន ៖ ឈ្មោះអីគេជំនាន់ហ្នឹង ចេះតាមដាន ឥឡូវឈប់ធ្វើអស់ហើយជំនាន់ពេលផ្តាច់ខ្លួន ឥឡូវឈប់អស់ ពីយប់ឡើងគេមកយាមមកស៊ើបមកមើលគេសុទ្ធថាប្តីយើងមកជួបយើង មកមើលមកអី មិនដែលគាត់ទៅនៅហ្នឹងដូចស្វាត់ឆឹងទៅ ហើយគេចេះមកស៊ើបមកនេះហ្នឹង ។

ទូច ៖ ខ្ញុំទើបគេផ្តាច់ខ្លួនបានមក ។

វ៉ុន ៖ ដល់ផ្តាច់ខ្លួនបានគាត់មកវិញ ស្អីឡូធ្វើទៀតឈប់ហើយ ។

ឈុនលី ៖ ចឹងដល់ពេលអាវីកព្រះវិហារអីនេះហ្នឹង ពូអត់មានឈ្មោះអីនេះហ្នឹង ពូអត់មានឈ្មោះអីទៀតទេ ផ្តាច់?

វ៉ុន ៖ អត់ទេ គាត់ចាស់ហើយ គាត់ឈប់ធ្វើឈប់អីមិនដែលទៅទេ ។

ឈុនលី ៖ គេមករករឿង គេខ្លាចយើងទៅចូលខាងនោះ ។ ចុះដល់ពេលផ្តាច់ខ្លួនភ្លាមហ្នឹង បានន័យថាគេជំរះអាមីនអស់ច្រើនហើយណា?

វ៉ុន ៖ ចា៎! អត់ ។

ឈុនលី ៖ ហើយពេលហ្នឹងមានថៃចេញចូលអីទៀតអត់ ពេលដែលយើងផ្ដាច់ខ្លួនហើយចឹង?

ទូច ៖ ថៃណា?

ឈុនលី ៖ មានថៃមានអីចូលមកដីយើងអត់កាលហ្នឹង?

ទូច ៖ ទេ! វាមកលេងធម្មតា ។

រ៉ុន ៖ មករកស៊ី មកលក់របស់របរឲ្យប្រជាជនយើងមកលក់ម្ហូបលក់អី មកប្រជាជនថៃមក ។

ឈុនលី ៖ ចុះដល់ពេលអាកន្ទែងនៅជិរំហ្នឹង ខាងអង្គការណាអ្នកឲ្យស្បៀងឲ្យអីចឹង?

ទូច ៖ ទេ! មិនដឹងខាងណាខាងណែទេ ។

ឈុនលី ៖ កាកបាទក្រហម?

រ៉ុន ៖ កាកបាទក្រហម គេហៅកាកបាទផ្ដល់ ។

ឈុនលី ៖ អាហ្នឹងនៅថៃម៉ង ទីស្នាក់ការវា?

ទូច ៖ ថៃ គ្រាន់ថា៩បារាំងអីហ្នឹង ។

ឈុនលី ៖ ចុះកាលហ្នឹងក្រែងគេមានអ្នកខ្លះគេបានទៅអាមេរិចបានទៅអីនោះ?

ទូច ៖ ហ្នឹងគេអ្នកណាអត់នៅគេទៅ ។

រ៉ុន ៖ គេអ្នកមានគេយកទៅហ្នឹងឯង ជំនាន់ហ្នឹងឲ្យនៅជិរំ គេអ្នកណាមាននេះគេទៅហើយ ។

ទូច ៖ ទាល់តែអ្នកមានអ្នកអី បើ៧៩ហ្នឹងបានគេដឹកទៅម៉ងអាហ្នឹង ។

ឈុនលី ៖ ៧៩គេដឹកទៅ?

ទូច ៖ បាទ! ៧៩ ឲ្យតែមានអ្នកចង់ទៅ ។

រ៉ុន ៖ ៧៩ ខ្ញុំអីនៅត្រាងនេះ គ្រាន់ថាយើងចង់ទៅ គេយកទៅ ។

ឈុនលី ៖ ចុះពូម៉េចអត់ចង់ទៅកាលនោះ?

ទូច ៖ ខ្ញុំអត់ ។

រ៉ុន ៖ អត់ដឹងរឿង យើងអត់បងប្អូនអត់អីមិនដឹងចង់ទៅអីស្រុកគេ ។

ទូច ៖ បើខ្ញុំចង់ទៅៗបាត់ ។

រ៉ុន ៖ ប៉ុនអ្នកនៅជាមួយទៅដែរហ្នឹង ។

ទូច ៖ ខ្លះគេហៅទៅគគោកខ្ញុំអត់ទៅ ។

ឈុនលី ៖ ទៅអាមេរិចកាលហ្នឹង?

ទូច ៖ ទៅអាមេរិច អត់ចង់ទៅអត់ ។

ឈុនលី ៖ បើទៅឥឡូវហ្នឹងគ្រាន់ដែរហ្នឹង?

ទូច ៖ ហ្នឹង ស្តាយដែរហ្នឹង ។

រ៉ុន ៖ វានេះគ្រាន់មានដែរហ្នឹង អត់ដឹងរឿងទៅបាត់ហើយ ។

ទូច ៖ វានៅព្រៃវែងនាចង់ងាប់ ។

រ៉ុន ៖ ខ្ញុំអ្នកនៅជាមួយខ្ញុំគេទៅឡើងគគោកឃើញគេទៅ ។

ឈុនលី ៖ គេមកវិញគេមាន?

រ៉ុន ៖ មានហើយ ។

ឈុនលី ៖ ភាគច្រើនអ្នកដែលទៅជំនាន់ហ្នឹងចឹងគេឲ្យអីចឹង
រហូតមកដល់ឥឡូវមានផ្ទះមានអីស្រួលបួល អីចឹង ធូរធា?

ទូច ៖ បាទ!

ឈុនលី ៖ ចឹងពូ ខ្ញុំសួរពូដូចឆោតចុះ ដូចថាពូខាងទាហានខ្មែរក្រហមមែន តែពូអត់សូវពេញចិត្តជាមួយខ្មែរក្រហមទេ?

ទូច ៖ ទេ! ពេញចិត្តបាននៅធ្វើ ។

ឈុនលី ៖ តែយើងដល់ពេលពិបាកពេក ចង់?

ទូច ៖ ពិបាកចេះតែទីង ចង់ទៅមិនដឹងទៅណារួច យើងទៅមិនរួច ។

រ៉ុន ៖ យើងចង់ចេញ មិនដឹងចេញទៅណា ។

ឈុនលី ៖ ចុះចឹងពូគិតថាខ្មែរក្រហមគាត់ល្អ ឬមួយក៏ម៉េចដែរ?

ទូច ៖ និយាយទៅដូចមិនមានអីថាអាក្រក់អី ។

ឈុនលី ៖ ចំនុចល្អណាខ្លះដែលពូគិតថាពូអាច ថាពូពេញចិត្ត?

ទូច ៖ ល្អខ្ញុំឃើញដាក់ស្តែងខ្លួនយើង មិនដែលឃើញធ្វើបាបប្រជាជនអីណា ចេះថាចេះថាចុះតាមពិតខ្លួនខ្ញុំផ្ទាល់ម៉ង ខ្ញុំឃើញមិនដែលមានអ្នកណាថាចឹង ។

ឈុនលី ៖ ចុះក្នុងជំនាន់ហ្នឹង ពូដែលឮថាគេថាខ្មែរក្រហមសម្លាប់មនុស្សអីចឹងៗ?

ទូច ៖ ហ្នឹងឮ ប៉ុនបើឃើញខ្លួនឯងវាមិនដែលឃើញ ។

ឈុនលី ៖ ហើយពូជឿទេកាលហ្នឹង?

ទូច ៖ ហ៊ឺ! ជឿខ្លះ អត់ជឿខ្លះដែរ ព្រោះវាកន្លែងខ្លះវាមិនបានឃើញ គ្រាន់ថាបានដឹងមានបងប្អូនប្រាប់ៗវាមានដាក់ស្តែងដែរ បានការសម្លាប់អី ។

ឈុនលី ៖ ចុះពូមានដឹងទេ ថាហេតុអីបានខ្មែរក្រហមសម្លាប់អីចឹង?

ទូច ៖ វាមិនដឹងហេតុអី គេថាក្បត់គេ ចោទថាក្បត់ម៉ាត់ហ្នឹងមានអី ។

ឈុនលី ៖ ហើយចឹងមានចំនុចណា ដែលពូអត់ពេញចិត្ត?

ទូច ៖ ហ៎! គ្មានស្អី មិនពេញចិត្តមានតែរឿងប្រើវាគ្មានពេលវេលា បង្ខំយើងចឹងទៅ ពិបាកវេទនាចឹងទៅ ។

ឈុនលី ៖ ច្បាំងរហូត?

ទូច ៖ ពេលស្រួលភ្លេចអារឿងលំបាកហ្នឹងទៅ ។

ឈុនលី ៖ ចុះរឿងទ័ពមួយគឺថាហូបចុកគ្រប់គ្រាន់ម៉ង ខ្វះអីម្ដងម្កាលអីចឹង?

ទូច ៖ ទេ! បើខ្វះម្ដងម្កាលវា ។

ឈុនលី ៖ តែវាមិនអត់ពេកទេ?

ទូច ៖ បាទ! អឺ! រឿងអត់ពេកអត់ទេ ។

ឈុនលី ៖ អត់ដែលដាច់បាយណា?

ទូច ៖ អត់ទេ ដាច់ម្ដងម្កាល ។

ឈុនលី ៖ បេះផ្លែឈើហូប?

ទូច ៖ បាទ! អា៧/៩ដាច់មែន ។

ឈុនលី ៖ អាពេលបែកដាច់ក្លាម អាពេលបែកវៀតណាម?

ទូច ៖ បាទ!

ឈុនលី ៖ ចុះឥឡូវពូមានកូនប៉ុន្មាននាក់?

ទូច ៖ ខ្ញុំ ៦ហើយ ។

ឈុនលី ៖ ៦នាក់?

ទូច ៖ បាទ!

ឈុនលី ៖ ធំៗអស់ហើយ?

ទូច ៖ ធំបានប្រពន្ធ៣ នៅ៣អាតូច ។

ឈុនលី ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ទូច ៖ សុទ្ធតែប្រុសទាំងអស់៦នាក់ ។

ឈុនលី ៖ ហើយចុះពូមានកូនចៅទៅធ្វើការនៅថៃ?

ទូច ៖ មាន ប៉ុនទៅមកវិញអស់ហើយ នៅផ្ទះ នៅតែប្អូនៗមិនទាន់មក ។

ឈុនលី ៖ ធ្វើការអីគេនៅ?

ទូច ៖ ការកសាងធ្វើផ្ទះធ្វើអីហ្នឹង ។

ឈុនលី ៖ ធ្វើសំណង់?

ទូច ៖ បាទ! សំណង់ ខ្លះក៏ធ្វើសំណង់ ខ្លះក៏ចាំចំការអីគេចឹងទៅ ទាំងប្អូនខ្ញុំបង្កើត ប្អូនថ្លៃ ចុះគ្នាអត់នៅនេះ មានអីទៀតទៅ ។

ឈុនលី ៖ ចឹងភាគច្រើនអ្នកស្រុកនៅនេះ គាត់ទៅធ្វើការនៅថៃ?

ទូច ៖ បាទ! នៅនេះមិនសូវខ្សត់ទេ ច្រើនមកពីយើងក្មេងៗ ។

ឈុនលី ៖ បាត់ដំបងអី?

ទូច ៖ បាទ! មកតាំងពីណាពីណោ មិនជិតទេ អាខ្លះយកមនុស្សទៅលក់ទៅអីណា កូនចៅខ្ញុំរកស៊ីនៅហ្នឹងថៃ តាំងពីដ្ដាច់ខ្លួនមក ។

ឈុនលី ៖ ចាំ!

ទូច ៖ ដើររកស៊ី ចុះយើងនៅស្រុកយើងដឹងរកអី ទៅថៃចឹងទៅបានលុយបានកាក់ ទិញនេះទិញនោះ ។

ឈុនលី ៖ តែអ្នកស្រុកភូមិនៅនេះអី ទៅថៃអត់ដែលមានបញ្ហា?

ទូច ៖ ទេ! ខ្លះថា ខ្លះមាន ។

ឈុនលី ៖ ដូចអ្នកខ្លះថាថៃធ្វើបាបអីចឹង?

ទូច ៖ បាទ! មានគេមិនដែលអត់ ។

ឈុនលី ៖ ចុះនៅម្តុំជិតៗនេះដែលមានដែរ?

ទូច ៖ មានម៉េច?

ឈុនលី ៖ ដែលមានដែលរឿងធ្វើបាប?

ទូច ៖ មាន ។

ឈុនលី ៖ មានស្លាប់មានអី?

ទូច ៖ ទេ! អត់មានដែលធ្វើបាប វ៉ៃ........ចាប់បានវ៉ៃធ្វើបាប ។

ឈុនលី ៖ ហើយដល់ពេលគេចូលមកយើងវិញ?

ទូច ៖ គ្មានអ្នកណាហ៊ានទេ ។

ឈុនលី ៖ ម៉េចចឹងពូ?

ទូច ៖ ដឹង មិនយល់ដូចជាដឹកនាំយើងហ្នឹង ។

ឈុនលី ៖ ដល់គេចូលមកយើងអត់អីទេ?

ទូច ៖ បាទ! អឺ!ចូលមកយើងដើរដូចជីវា ហើយយើងទៅស្រុកគេទៅធ្វើការ ។

ឈុនលី ៖ ឆ្លងតែអូរហ្នឹងតិចអត់បានដែរ?

ទូច ៖ អត់បានទេ យើងចូលទៅគេ តែចូលបានស្រួលមានតែផ្លូវផ្សារឡាក់ណាត់ទេ ចូលផ្សារវិញគេបាន ។

ឈុនលី ៖ ផ្សារអីគេអាហ្នឹង?

ទូច ៖ ផ្សារឡុងពើ ។

ឈុនលី ៖ ផ្សារឡុងពើ?

ទូច ៖ បាទ! ភូមិដូង ។

ឈុនលី ៖ ផ្សារឡុងពើ ផ្សារយូរហើយ?

ទូច ៖ ផ្សារទើបបង្កើតប៉ុន្មានឆ្នាំ ។

រ៉ុន ៖ ផ្សារទើបបង្កើតឥឡូវនេះហ្នឹង ។

ទូច ៖ ទើបបានប៉ុន្មានឆ្នាំ ។

រ៉ុន ៖ ពីមុនអត់ ថៃដើរលក់នេះ ដើរលក់តាម ។

ទូច ៖ លក់តិចតាមអូរ ។

រ៉ុន ៖ វាមកលក់តាមព្រំដែនចឹង វាមកលក់តាមមាត់អូរចឹងទៅ ខ្មែរយើងទៅទិញទៅ ផ្សារទើបកើតឥឡូវនេះដែរហ្នឹង ៣-៤ឆ្នាំ ។

ទូច ៖ ហើយនៅស្រុកនេះពីដើមវាមិនសូវលក់ដូរ បន្លែបន្ការដាំ សុំគ្នាហូបហ្នឹង មិនមែនដូចឥឡូវសូម្បីតែត្រកួនក៏ទិញគេដែរ ។ លុងស្អីក៏ដោយ ចេកអី អ្នកណាចង់ហូបកាប់ហូបតាមផ្ទះហ្នឹង គ្មានពិបាកណាទិញណាទេ មិនមែនដូចឥឡូវនេះទេ ។

រ៉ុន ៖ ហើយឥឡូវយើងផ្តាច់ខ្លួនទៅ អ្នកនៅខាងនោះគេមកនៅច្រើនមកនៅមករកស៊ី អ្នកនៅតាមផ្សារ....... ។

ទូច ៖ ឥឡូវសូម្បីតែកូនចេកមួយក៏លក់ដែរ ។

រ៉ុន ៖ ពីមុនអីចឹងសុំគេហូបបាន សុំគេដាំបាន ។

ទូច ៖ បើផ្ទះខ្ញុំផងដាំ និយាយពីគ្រប់ ននោងផ្លែគេបេះយកបបរបាយជ្រូក អាហ្នឹងគេចិញ្ចឹមជ្រូកហើយជ្រូកចិញ្ចឹមបានមិនដឹងយកទៅណា កាប់សាច់ចែកគ្នាស៊ីទៅវាចឹង មិនដឹងលក់ណាបេះដាំកើត...ដាក់ទៅបានហូបទាំងអស់ ។ ផ្ទះខ្ញុំមិនខ្វះអីហូបទេ ចេក ។

ឈុនលី ៖ ពូចុះភ្លេចហើយនឹកឃើញមិញ ភ្លេច ចង់សួរអីគេចេះ កាលហ្នឹងពូអត់ដែលនៅជាមួយប្រជាជនអីផងហ្នឹងចឹង?

ទូច ៖ អត់ ។

ឈុនលី ៖ ចុះពេលធ្វើទំនប់អីចឹង ពូដែល អាហ្នឹងមិនមានអ្នកស្រុកមានអីដែរ?

ទូច ៖ មានអ្នកស្រុក មានគេហៅកងចល័ត ។

ឈុនលី ៖ ចុះពូដែលជួយដូចថាមានដែលធ្វើអីជួយយកបាយឲ្យគេហូបអីចឹង?

ទូច ៖ អត់ទេធ្វើដូចគ្នា យើងកងទ័ពក៏ធ្វើទំនប់ហ្នឹងទាំងអស់គ្នា ។

ឈុនលី ៖ យើងតែយើង គេតែគេទៅ?

ទូច ៖ បាទ! គេធ្វើជាមួយគ្នារួមគ្នាទាំងអស់ ចំរុះគ្នា ។

ឈុនលី ៖ ក្រោយយើងផ្តាច់ខ្លួនហើយអីចឹង ដូចពូដែលជួបខ្មែរយើងធម្មតាដូចប្រជាជនអីចឹង ហើយដូចរបៀបចង់និយាយថា បើទំនាក់ទំនងរវាងយើងជាមួយគេម៉េចដែរ?

ទូច ៖ ទេ! មានអីវា ។

ឈុនលី ៖ ធម្មតា?

រ៉ុន ៖ បាទ! ធម្មតា ។

ឈុនលី ៖ តែមើលទៅគេដូចខឹងខាងខ្មែរក្រហមអត់ មើលទៅ?

ទូច ៖ ទេ! មានខឹងអី ខឹងខ្មែរក្រហមៗយើងទៅមានខឹងទេ ខឹងតែមេតើ ។

ឈុនលី ៖ ខឹងតែមេ?

ទូច ៖ យើងមានបានសម្លាប់អី មានតែមេៗ បើអ្នកដែលធ្វើបាបប្រជាជនគ្មានអ្នកណាហ៊ានទៅ ។

ឈុនលី ៖ អ្នកណាគេទៅ?

ទូច ៖ ងាប់អស់ឥឡូវ ។

ឈុនលី ៖ ឈ្មោះអីទៅដែលងាប់អស់?

ទូច ៖ ឈ្មោះអីទេ អូ!កាលហ្នឹងម៉ាចំនៀរយើងខាងលិចនេះ ប្រជាជនស្គាល់ទាំងអស់គ្មានហ៊ានទៅទេ ប៉ុនងាប់ហើយងាប់យូរហើយ ។

ឈុនលី ៖ អត់ចាំឈ្មោះទេ ពូ?

ទូច ៖ ភ្លេចហើយដូចឈ្មោះដន ទេដឹង ។

ឈុនលី ៖ ឈ្មោះដន?

ទូច ៖ បាទ!

ឈុនលី ៖ គាត់ធ្វើអីបានខ្លាំងម៉េច?

ទូច ៖ ហ៎! ចៅហ្វាយស្រុក អឺ!កាលហ្នឹងគេហៅគណៈស្រុកៗ ។

ឈុនលី ៖ អាហ្នឹងក្នុងកំឡុងឆ្នាំអី គណៈស្រុក?

ទូច ៖ ឆ្នាំ៧៥ ៧៦ ៧៧ រហូតដល់៧៩ហ្នឹងបានរត់មក ប្រជាជនគ្រាន់ត្រូឈ្មោះ៧៩ដូរគោ ។

ឈុនលី ៖ ដូរគោម៉េច?

ទូច ៖ ប្រជាជនក្នុង ដូរយកមនុស្សហ្នឹងយកគោទៅដូរៗយកមនុស្សទៅវ៉ៃចោល ។

វ៉ុន ៖ សម្លាប់ៗមនុស្សដូរយកទៅវ៉ៃចោលរហូត ។

ទូច ៖ សម្លាប់ធ្វើបាបគេនោះ ធ្វើបាបបងប្អូនគេ ម៉ែឪគេ ។

វ៉ុន ៖ ធ្វើបាបគេពេក គេសម្លាប់ ។

ឈុនលី ៖ ចឹងគាត់ស្លាប់ដោយសារអីគេ?

ទូច ៖ ស្លាប់ស្អីកើតស្អីបេះដូង ។

ឈុនលី ៖ ចឹងគាត់គណៈស្រុកនៅម៉ាខ្សែហ្នឹងម៉ង?

វ៉ុន ៖ ហ៎! មិនមែនទេ នៅបវេល ។

ឈុនលី ៖ ចុះគណៈស្រុកនៅនេះតាំងពី៧៩ពីណាគេទៅ?

ទូច ៖ ទេ!នេះពីដើមមកគ្មានគណៈស្រុកទេ អត់ទេ ។

វ៉ុន ៖ ៧៩អត់ទាន់មានគណៈស្រុកទេនេះ ។

ឈុនលី ៖ គណៈតំបន់ពូ?

ទូច ៖ តំបន់ក៏អត់មាន ទើបកើតយើងមុនយើងផ្តាច់ខ្លួនមានស្រុក ។

ឈុនលី ៖ ចុះបើអ្នកគ្រប់គ្រងតំបន់ហ្នឹងម៉ង?

ទូច ៖ តំបន់ហ្នឹង?

ឈុនលី ៖ ចា៎! ខាងប៉ែកម៉ាខ្សែខាងអីចឹង?

ទូច ៖ មាន សុខ ភាពហ្នឹង ហើយនឹងមេៗធំៗទៀត ។

ឈុនលី ៖ ខាងកងទ័ពមានខាងទ័ព ។ មេធំអ្នកណាគេទៅ?

ទូច ៖ មេធំកាលនៅនេះមានអៀង វុធ អី ។

ឈុនលី ៖ អៀង វុធ?

ទូច ៖ បាទ!

ឈុនលី ៖ គាត់បងប្អូនជាមួយអៀង សារីដែរ?

ទូច ៖ កូន ។

វ៉ុន ៖ កូនតាអៀង សារី

ឈុនលី ៖ អាហ្នឹងគាត់គ្រប់គ្រងតំបន់ម៉ង?

ទូច ៖ បាទ! ហើយហ្នឹងខ្មោចយាយថែម គាត់ស្លាប់អស់ហើយ ។

ឈុនលី ៖ អៀង វុធហ្នឹងបើនៅគាត់នៅណាវិញ?

ទូច ៖ អភិបាលក្រុងប៉ៃលិន រងរបស់អ៊ី ឈាន ។

ឈុនលី ៖ អភិបាលក្រុង រងរបស់អ៊ី ឈាន?

ទូច ៖ បាទ!

ឈុនលី ៖ អៀង វុធ អាហ្នឹងគេហៅគណៈតំបន់ របៀបរងៗពីសុខ ភាព?

ទូច ៖ បាទ! ហើយគេរង ប៉ុនគេដូចអំណាចធំជាង ព្រោះ ។

ឈុនលី ៖ ឪគេធំ?

ទូច ៖ ឪធំ គាត់ហ្នឹងអ្នកទទួលខុសត្រូវហ្នឹងអៀង សារី ស្រុកម៉ាឡៃហ្នឹង ។

ឈុនលី ៖ អូ! អៀង សារីអ្នកគ្រប់គ្រង អ្នកទទួលខុសត្រូវ?

ទូច ៖ បាទ! គ្រប់គ្រង អត់មាននៅនេះណា ទៅនៅប្រទេសថៃ ។

ឈុនលី ៖ ហើយទាំងប្រពន្ធគាត់ទៀត?

ទូច ៖ ទាំងប្រពន្ធគាត់អីហ្នឹងនៅប្រទេសថៃ ។

ឈុនលី ៖ ហើយដល់ពេលធំបន្ទាប់មកមានតែអីគេ?

ទូច ៖ សុខ ភាព ។

ឈុនលី ៖ សុខ ភាព ហ្នឹងហើយ ។ ក្រោមៗទៀត?

ទូច ៖ តៗមកច្រើនដែរ ហ្នឹង ។

ឈុនលី ៖ ពូចាំឈ្មោះទេ?

ទូច ៖ មានតាមោង ។

ឈុនលី ៖ ដុន?

ទូច ៖ តាដុន តានីៗនោះគាត់អភិបាលស្រុក សព្វថ្ងៃគាត់ទៅនៅស្វាយ ។

ឈុនលី ៖ ធ្វើអីគេនៅស្វាយ?

ទូច ៖ ខាងអីគេទេ ទៅនៅកាន់ស្រុកភ្នំស្រុកបាន អឺ!នែកថ្មពួក ចេញពីថ្មពួកទៅនៅស្វាយវិញ
នៅជាមួយពុកសាលុយ មិនដឹងខាងអីគេឥឡូវ មិនដែល...ខាង........ចំការអីគេទេ ។

ឈុនលី ៖ កាលនៅពួកហ្នឹងគាត់ធ្វើចៅហ្វាយស្រុកដែរ?

ទូច ៖ ឈប់ហើយឥឡូវ ។

ឈុនលី ៖ កាលលើកមុន?

ទូច ៖ ណា៎?

ឈុនលី ៖ ឈ្មោះនីហ្នឹង?

ទូច ៖ បាទ! ចៅហ្វាយស្រុក ។

ឈុនលី ៖ ចៅហ្វាយស្រុក?

ទូច ៖ ចៅហ្វាយស្រុកម៉ាឡៃ ។

ឈុនលី ៖ តែចុះពូថាទៅនៅពួកនោះ?

ទូច ៖ គាត់ហ្នឹងធ្វើចៅហ្វាយស្រុកដែរ ។

ឈុនលី ៖ អូ! ទៅស្រុកពួក?

ទូច ៖ បាទ!

ឈុនលី ៖ មុននៅម៉ាឡៃឬក៏ក្រោយមក?

ទូច ៖ ទេ! ក្រោយតើ ដល់ពេលតាណាល់ឡើងនេះបានគាត់ទៅហ្នឹង គេដូរគាត់ ។ ទៅនៅបាន ប៉ុន្មានខែ ដាច់ម៉ាឆ្នាំ បានដកពីហ្នឹងមកទៅនៅខេត្ត ។

ឈុនលី ៖ ហើយឥឡូវទៅនៅស្វាយ?

ទូច ៖ បាទ! នៅស្វាយ ។

ឈុនលី ៖ ធ្វើចៅហ្វាយស្រុក?

ទូច ៖ អត់ធ្វើទេ មិនដឹងខាងអី អត់ដឹងនៅខាងខេត្ត ប៉ុន្តែដឹងទទួលខាងពិការខាងអីភ្លេចហើយ ទៅសួរពួកគេអ្នកធ្វើទាហានបានដឹង ខ្ញុំមិនបានធ្វើមិនដែលបានជួបគាត់សួរ ខ្ញុំមិនទាក់ទងពួកគាត់ ។

ឈុនលី ៖ ពូឧទាហរណ៍ថា បើយើងចង់ផ្សះផ្សាររវាងខ្មែរក្រហម និងខ្មែរៗធម្មតា តើពូគិតថាតើគួរតែរស់នៅជិតគ្នា ឬមួយក៏ឆ្ងាយគ្នា បានយើងងាយស្រួលផ្សះផ្សា?

ទូច ៖ ទាល់តែនៅកៀកគ្នាបានផ្សះផ្សាបាន........ ។

ឈុនលី ៖ របៀបម៉េចទៅពូ ផ្សះផ្សាររបៀបម៉េចទៅពូ?

ទូច ៖ ផ្សះផ្សាយើងទៅនិយាយ ជាមួយគ្នារឿងការកុំចោទគ្នាអានេះក្បត់ទៅ អានោះក្បត់អានេះ ។

ឈុនលី ៖ យើងសារភាពអីចឹង?

ទូច ៖ បាទ! សារភាពរៀនខ្លួនទៅណា ការពិសោធន៍មិនខុសពីយើង....សួរគ្នាបានរស់នៅជាមួយគ្នាបានថាហ៎!ខ្ញុំអាចខុសដែរ...... ចឹងបានយើងនៅជាមួយ ។ ដូចខ្ញុំនៅជាមួយខ្មែរក្រហមមែន ប៉ុនអ្នក ។

ឈុនលី ៖ ត្រូវគ្នាជាមួយអ្នកស្រុក?

ទូច ៖ អ្នកស្រុកនិយាយពីទាហានស្អីកក៏ដោយ នគរបាល មកដើរសួរតែកូនក្មេងប៉ុននេះក៏គ្មានអ្នកណាប្រាប់ថាខ្ញុំនៅហ្នឹង ។

ឈុនលី ៖ គេលាក់?

ទូច ៖ អូ! លាក់ដូចស្អីចឹង បានខ្ញុំទៅបានរាប់ឆ្នាំ ។

ឈុនលី ៖ ចុះដូចពូទៅលេងស្រុកទៅឆ្នាំណា ពូបានទៅលេងស្រុក?

ទូច ៖ ខ្ញុំទៅឆ្នាំប៉ុន្មានទេ ។ ធ្វើការនៅថៃអស់ស្ងាត់ ។

ឈុនលី ៖ ទៅហ្នឹងដូចទៅវិលល្ងាច ឬក៏រាប់ខែ?

ទូច ៖ អត់ទៅធ្វើរាប់ខែ ។

ឈុនលី ៖ ដល់បុណ្យទានបានមក?

ទូច ៖ បាទ! អាខ្លះក៏បានមក អាខ្លះមិនបានមកទេ ដូចកូនខ្ញុំគ្មានបានមកណា ។

«ចប់»